ត្រឹង ងា

សាស្ត្រាចារ្យបរិញ្ញាផ្នែកវប្បធម៌ និងអរិយធម៌អាស៊ី

សាស្ត្រាចារ្យប្រវត្តិសាស្ត្រខ្មែរនៅមហាវិទ្យាល័យអក្សរសាស្ត្រ និងមនុស្សសាស្ត្រ

# ប្រវត្តិសាស្ត្រខ្មែរ

( ពីដើមដល់ការបោះបង់ក្រុងអង្គរ )

ភាគ 1

ការផ្សាយរបស់អ្នកនិពន្ធ

រក្សាសិទ្ធិគ្រប់យ៉ាង

ភ្នំពេញ គ.ស.១៩៧៣ ព.ស.២៥១៧

# បុព្វកថា

សព្វថ្ងៃនេះ ប្រសិនបើយើងយកសៀវភៅផ្សេងៗដែលបោះពុម្ពផ្សាយក្នុងពិភពលោក ជាពិសេសសៀវភៅដែលបោះពុម្ពផ្សាយនៅក្នុងប្រទេសជិតខាងយើងនេះមកពិនិត្យមើល នោះយើងនឹងឃើញថាអ្នកនិពន្ធបរទេសគេមានទស្សនៈប្លែកៗ ចំពោះអត្ថិភាពបច្ចុប្បន្នរបស់ជាតិខ្មែរយើង ។

១. លោក I . Robbin បានសរសេរថា : « Les khmers disparurent en 1432 ,mais nuos savons pourquoi . Ils furent envahis et conquis par un peuple rival , les Thais . les rares survivants s'éparpillerent dans la jungle et cessèrent d'exister en tant querace ( Civilisations perdues , p . 46 , éditions R . S . T . ,1962 ) .

២. លោក E . Henri-Biaband បានសរសេរថា : « les khmers qui furent les architectes et les ouvriers de ces temples ( Angkor) vers l´an mille de notre ére , n'ont laissé d'écrits ni de plans , ni rien qui puisse nous livrer leur pensée....» ( Deux ans d'Indochine , édition I D E O , Hanoi 1939 )

៣. លោកហ្លួងវិចិត្រវាទការបានសរសេរថា : « It is an established fact that the khmers and the Cambodians are not the same people The coming in to existence of the new name « Cambudja » marked the end of the old khmer race and the birth of a new people who have 90% of thai blood »(Thailand's case , Bangkok ,1941 , p. 129-130)

៤. លោក Lê Huong បានសរសេរថា បុរាណវត្ថុវិទូ Maurice Glaize បានកត់ទុកថា "... ក្រោយពីបានបង្កើតរដ្ឋនៅឆ្នាំ ៥៩៨ នៃ គ.ស. ស្តេចចេនឡាបានទន្ទ្រានយកទឹកដីប្រទេសហ្វូណនបន្តិចម្តងៗ ដណ្តើមបានរាជធានីហើយបានសំលាប់បំផុតពូជប្រជាជនរដ្ឋនេះតែម្តង " ។ នេះជាទំនាស់ក្នុងគំនិតមួយយ៉ាងធំរបស់ជនជាតិបារាំង ដែលបានសរសេរពីបូព៌ាប្រទេស : កូនចៅបានសំលាប់បំផុតពូជដូនតារបស់ខ្លួនដើម្បីដណ្តើមយកទឹកដី ជាការមួយគួរអោយពិចារណាមែន( Nguoi viêt gôc Miên , saigon , 1969)

ដំណកស្រង់ទាំងប៉ុន្មានខាងលើនេះ បង្ហាញអោយឃើញថា ចំពោះជនបរទេសខ្លះ ជនជាតិខ្មែរបានស្លាប់ផុតពូជអស់ទៅហើយឬមួយជនជាតិខ្មែរសព្វថ្ងៃមិនមែនជាកូនចៅអ្នកកសាងអង្គរទេ គឺថាមិនមែនជា ខ្មែរសុទ្ធ ដែលជាតំណតមកពីដូនតាខ្មែរដើមឡើយ ។ ទស្សនៈទាំងនេះ ទោះបានបញ្ចេញដោយភ័ន្តច្រឡំក្តី ដោយលាក់គំនិតនយោបាយក្តី សុទ្ធតែនាំអោយមតិអន្តរជាតិយល់ខុសពីជាតិខ្មែរយើង ព្រមទាំងធ្វើអោយយើងដែលជាជនជាតិខ្មែរនេះ ត្រូវខូចបង់នូវកេរ្តិ៍ឈ្មោះថែមទៀតផង ។ ដូច្នេះ ឃើញថាយើងមានការចាំបាច់ត្រូវបំភ្លឺមតិអន្តរជាតិអោយដឹងថា ជាតិខ្មែរនៅមានអត្ថិភាពនៅ

ឡើយ យើងទាំងអស់គ្នាជាខ្មែរ រស់នៅក្នុងឋានៈជារដ្ឋអធិបតេយ្យ យើងនៅនិយាយនិងសរសេរភាសាខ្មែរ កាន់ទំនៀមទំលាប់ប្រពៃណីខ្មែរ ។ ក្រៅពីជនជាតិខ្មែរ ក្នុងរង្វង់ព្រំដែនសាធារណរដ្ឋខ្មែរ យើងនៅមានបងប្អូនរួមឈាមយើងនៅក្នុងប្រទេសជិតខាងទៀត : ប្រហែល ៣លាននាក់នៅក្នុងសាធារណរដ្ឋវៀតណាមខាងត្បូងនិងជិត៤លាននាក់ទៀតនៅក្នុងប្រទេសថៃ ។

យើងយល់ថា នឹងអាចបំភ្លឺមតិអន្តរជាតិបាន លុះណាតែយើងបានចេះចាំច្បាស់ប្រវត្តិសាស្ត្រដែលជាធម៌សំយោគមួយរវាងវប្បធម៌និងសង្គមធម៌របស់ជាតិនេះឯង ។ យ៉ាងណាមិញក្នុងចំណោមវិធីផ្សេងៗសំរាប់ស្គាល់ជំរៅនៃជាតិសាសន៍ណាមួយនោះ គឺមានប្រវត្តិសាស្ត្រនេះមួយដែរ ព្រោះដរាបណាយើងសិក្សាប្រវត្តិសាស្ត្រអោយបានហ្មត់ចត់ទៅ ដរាបនោះយើងនឹងអាចស្គាល់នូវ :

១. កិច្ចការទាំងឡាយរបស់ដូនតាយើងមាន ឆ្ការព្រៃ ជីកព្រែក បារាយណ៍ លើកផ្លូវ សង់ស្ពាន កសាងប្រាសាទរាប់រយរាប់ពាន់ ដែលមានសល់ជាកេរដំណែលពាសពេញលើទឹកដីយើង រហូតដល់សព្វថ្ងៃ ។

២. ការតស៊ូនិងពលិកម្មគ្រប់បែបយ៉ាងដែលដូនតាយើងធ្លាប់តែធ្វើរាប់សតវត្សមកហើយក្នុងការប្រឆាំងទប់ទល់នឹងធម្មជាតិផងនឹងខ្មាំងសត្រូវជិតខាងដែលតែងតែចូលមកយាយីបំរុងលេបយកទឹកដីយើងផង ។

ម្យ៉ាងទៀត ប្រវត្តិសាស្ត្រក៏ជាមធ្យោបាយមួយសំរាប់អប់រំអោយប្រជាពលរដ្ឋមានចិត្តស្រឡាញ់ទឹកដី ភូមិស្រុកដែលខ្លួនកំពុងតែរស់នៅនិងអ្វីៗផ្សេងទៀតមានវប្បធម៌នេះជាដើម ដែលដូនតាយើង លោកបានកសាងទុកជាកេរដំណែលដល់យើងក្នុងជំនាន់នេះ ។ បើកាលណាយល់តម្លៃនិងស្រឡាញ់អ្វីជាគ្រឹះរបស់ជាតិហើយ គេនឹងខិតខំការពាររបស់នោះ ដោយពុះពារឧបសគ្គគ្រប់បែបយ៉ាង ដើម្បីតស៊ូនឹងសត្រូវឈ្លានពាននិងដើម្បីខំកសាងជាតិអោយបានថ្កុំថ្កើងរុងរឿងឡើងវិញ ។

គឺដើម្បីធ្វើអោយសំរេចនូវគោលបំណងខាងលើនេះ ទើបយើងបានសំរេចបោះពុម្ពផ្សាយនូវសៀវភៅ " ប្រវត្តិសាស្ត្រខ្មែរ "ភាគ១ នេះដោយសង្ឃឹមថាកិច្ចការនេះនឹងបានជាការរួមចំណែកមួយក្នុងការបំរើជាតិដែរ ។

ប៉ុន្តែយើងជឿជាក់ថា ក្នុងជំហានដំបូងនេះមុខជាមានកង្វះខាតទាំងខាងគំនិត ទាំងខាងបច្ចេកទេស ដែលយើងសូមអោយមិត្តអ្នកអានមេត្តាខន្តីអភ័យទោសទុកជាមុន ព្រមទាំងជួយផ្តល់យោបល់រិះគន់ឬឯកសារថែមទៀតដែលយើងរង់ចាំទទួលជានិច្ច ។

ភ្នំពេញថ្ងៃទី ២៥ ខែ តុលា ១៩៧៣

**អ្នកនិពន្ធ**

# ជំពូក ១

# មជ្ឈដ្ឋានភូមិសាស្ត្រ និងដើមកំណើតជាតិខ្មែរ

## ក. មជ្ឈដ្ឋានភូមិសាស្ត្រ

ក្នុងសម័យដែលរុងរឿងបំផុត ទឹកដីខ្មែរបានលាតសន្ធឹងទៅលើមួយភាគធំនៃអាស៊ីអគ្នេយ៍ដីគោក ។ ក្រៅពីប្រទេសខ្មែរបច្ចុប្បន្ន ទឹកដីកូសាំងស៊ីនទាំងមូល ផ្នែកខាងត្បូងនិងកណ្ដាលនៃប្រទេសលាវ និងផ្នែកខាងកើតនៃប្រទេសថៃ ក៏ជារបស់ខ្មែរដែរ ។ ហើយមានពេលខ្លះ អំណាចខ្មែរបានលាតសន្ធឹងរហូតដល់ជ្រោយម៉ាឡាយូនិងប្រទេសភូមាថែមទៀតផង ។

ពីស. វ. ទី១៣ ដល់១៩ ទឹកដីខ្មែរត្រូវរួញបន្តិចម្ដងៗដោយសារអំពើរុករានរបស់ជនជាតិសៀម និងជនជាតិយួន ដែលមានបំណងចង់យកទន្លេមេគង្គធ្វើជាព្រំដែនរួមរបស់គេ ។ ដោយមានការស្នើសុំពីសំណាក់ស្ដេចខ្មែរ ហើយដែលស្របនឹងប្រយោជន៍របស់គេផងនោះ បារាំងបានធ្វើអន្តរាគមន៍ចូលមកក្នុងនយោបាយខ្មែរហើយប្រហែលដោយសារនោះ ជាតិខ្មែរយើងក៏អាចនៅគង់វង់រហូតដល់សព្វ ថ្ងៃ ព្រមទាំងអាចថែរក្សាទឹកដី ដែលខ្លួនធ្លាប់មានកាលពីស. វ. ទី១៨ ។ ប៉ុន្តែជនជាតិខ្មែររាប់លាននាក់ត្រូវឃ្លាតឆ្ងាយពីមាតុភូមិរបស់ខ្លួន ហើយត្រូវរស់នៅក្រោមការគ្រប់គ្រងរបស់ជនបរទេសដែលបានយកទឹកដីខ្មែរធ្វើជាទឹកដីរបស់គេ ។

ប្រទេសខ្មែរសព្វថ្ងៃមានផ្ទៃដីប្រមាណ១៨២. ០០០គ. ម. ក្រឡា ហើយស្ថិតនៅចន្លោះប្រទេសថៃ ប្រទេសលាវ ប្រទេសវៀតណាមខាងត្បូងនិងឈូងសមុទ្រថៃ ។ បើនិយាយពីសណ្ឋានដី គេឃើញមានភូមិភាគពីរ ខុសប្លែកគ្នា : មួយផ្នែកជាដីខ្ពស់នៅខាងជើង ឦសាន និងនិរតី មួយផ្នែកទៀតជាដីទំនាប តំបន់បឹងទន្លេសាប អាងទន្លេមេគង្គនិងតំបន់ឆ្នេរសមុទ្រ ។

ភូមិភាគដីខ្ពស់ជាភូមិភាគសម្បូណ៌ដោយព្រៃឈើ ហើយមានសណ្ឋានហាក់ដូចជារបងព័ទ្ធជុំវិញដីទំនាប ។

នៅទិសនិរតី ជួរភ្នំក្រវាញបានលាតសន្ធឹងតាមឆ្នេរសមុទ្រ តែមានកំពស់មធ្យមមិនហួសពី ១០០០ម.ឡើយ ។

នៅខាងជើង ជួរភ្នំដងរែកជាព្រំដែនធម្មជាតិរវាងប្រទេសខ្មែរនិងប្រទេសថៃ ។ នៅខាងត្បូងជួរភ្នំនេះ គេឃើញមានភ្នំ(ភ្នំដែក)និងខ្ពង់រាបខ្លះ(ភ្នំគូលែន) ។

នៅទិសឦសាន ខ្ពង់រាបក្រានិត( granite) បានលាតសន្ធឹងក្នុងខេត្តរតនគីរីនិងមណ្ឌលគីរីហើយមានកន្លែងខ្លះមានកំពស់រហូតដល់១០០០ម.(កន្លែងប្រជុំព្រំដែន ៣) ។ ខ្ពង់រាបទាំងនេះជាប្រភពនៃស្ទឹង ៣ដែលបានហូរឆ្ពោះទៅរកទន្លេមេគង្គ គឺស្រែពក សេសាន និងសេកុង ។

ផ្នែកកណ្តាលនៃប្រទេសខ្មែរ មានសណ្ឋានជាចានដែកធំមួយ ដែលគេឃើញមានភ្នំនៅត្រង់ណោះខ្លះ នៅត្រង់ណោះខ្លះ ។ គឺនៅត្រង់នោះហើយដែលមានមនុស្សរស់នៅច្រើនកុះករជាទីបំផុត ហើយដែលចិញ្ចឹមជីវិតដោយរបរកសិកម្ម ព្រោះជាដីមានជីជាតិ និងមានទំហំធំទូលាយជាងគេនៅឥណ្ឌូចិនទាំងមូលនេះ ។

ទន្លេមេគង្គជាទន្លេធំតែមួយដែលបានឆ្លងកាត់វាលទំនាបខ្មែរពីខាងជើងរហូតដល់ចុងខាងត្បូង ។ ទន្លេនេះមានប្រវែងជាង៥០០០គ.ម.មានប្រភពចេញមកពីខ្ពង់រាបទីបេ ហើយបានហូរកាត់ប្រទេសចិនខាងត្បូង ប្រទេសភូមា ប្រទេសថៃ ប្រទេសលាវ ប្រទេសខ្មែរ និងប្រទេសវៀតណាមខាងត្បូង ។ នៅត្រង់ខោនក្នុងប្រទេសលាវ ដុំថ្មជាច្រើនបានរាំងផ្លូវទន្លេមេគង្គជាប់ បង្កើតបានជាអាងទឹកកំពស់ប្រមាណ២០ម.ហើយដែលជាហេតុបណ្តាលអោយមានល្បាក់ទឹក មិនអាចអោយកប៉ាល់ធ្វើចរាចរណ៍ទៅមកបានឡើយ ។ ដីសណ្តរទន្លេមេគង្គមានដៃច្រើន ខ្លះមានទទឹងដល់ទៅ ២គ.ម. ហើយមានទំហំប្រមាណជា ៦០០គ.ម. ។

វាលទំនាបទន្លេមេគង្គ បានលាតសន្ធឹងពីក្រចេះរហូតដល់សមុទ្រចិន ។ នៅភ្នំពេញ ទន្លេនេះបានបែកជាបួនត្រង់កន្លែងដែលគេហៅថា "ទន្លេ៤មុខ "(ទន្លេធំ-ទន្លេសាប-ទន្លេតូច-ទន្លេបាសាក់) ។

នៅខែមីនា-មេសា ទឹកទន្លេមេគង្គ ស្រកចុះច្រើនហើយនៅនឹងមួយកន្លែង ។ លុះចូលដល់រដូវភ្លៀងជោកជាំនៅខែកក្កដា ទឹកទន្លេឡើងខ្លាំង ធារទឹកអាចឡើងដល់៥០.០០០ម៉ែត្រត្រីគុណក្នុង១វិនាទី(លើសទន្លេក្រហមទៅទៀតដែលមានធារទឹកតែត្រឹម ៣០.០០០ម៉ែត្រត្រីគុណក្នុង១វិនាទី): ទន្លេតូច និងទន្លេបាសាក់មិនអាចនាំទឹកហូរទៅក្នុងសមុទ្រចិនបានទាំងអស់ ទឹកនោះក៏ហូរចូលទៅក្នុងបឹងធំ ៗ (បឹងធំ-បឹងតូច)តាមរយៈទន្លេសាប ។ ដូច្នេះបឹងទន្លេសាបជានិយតករ (régulateur) មួយយ៉ាងសំខាន់ទប់ទល់កុំអោយមានទឹកជំនន់ក្នុងរដូវវស្សា ។

តាមការសិក្សារបស់អ្នកភូមិសាស្ត្រ បឹងទន្លេសាបជាស្នាមនៃឈូងសមុទ្រមួយត្រូវបិទជិតដោយដីល្បាប់ ដែលទន្លេមេគង្គនាំមកលប់ជារៀងរាល់ឆ្នាំ។ បឹងនេះមានប្រវែងសរុប១៦០គ.ម.(បឹងធំ+បឹងតូច +វាលភក់)ហើយមានទទឹងជាអតិបរមា៣៥គ.ម. ។ នៅរដូវសំរក(មីនា-មេសា)ទំហំផ្ទៃទឹកមានប្រមាណ ៣.០០០គម[២] ។ នៅរដូវទឹកឡើង(កក្កដា) នៅពេលដែលទឹកទន្លេមេគង្គហូរចូល កំពស់ទឹកឡើងពី ២ដល់១៤ម. ទឹកហៀរចេញពន្លិចតំបន់ជិតខាងរហូតដល់ ២០ឬ ៣០គ.ម. ។ នៅខែតុលា - វិច្ឆិកា ទឹកហូរចេញពីបឹងទន្លេសាបចូលទៅក្នុងទន្លេមេគង្គវិញ គឺក្នុងឱកាសនោះហើយដែលប្រជារាស្ត្រខ្មែរនាំគ្នាប្រារព្ធធ្វើពិធីបុណ្យអុំទូក- សំពះព្រះខែ លយប្រទីប ។

គួរកត់សំគាល់ថា បឹងទន្លេសាបជាកន្លែងដែលមានត្រីច្រើនជាងគេក្នុងពិភពលោកបើគិតតាមសមាមាត្រនៃទំហំបឹងនេះ ។ ម្យ៉ាងទៀត នៅប្រទេសខ្មែរយើងភ្លៀងធ្លាក់ទៀងទាត់ជាងនៅប្រទេសវៀតណាមខាងជើង ដូច្នេះហើយបានជាទឹកជំនន់នៅទន្លេមេគង្គមានភាពមិនសូវសាហាវដូចនៅទន្លេក្រហមទេ ។ គេមិនបាច់ធ្វើទំនប់ហើយដើម្បីពង្រីកយកដីដាំដំណាំ គេគ្រាន់តែបង្ហូរទឹកចេញពីកន្លែងណាដែលលិចទឹកនិងបញ្ចូលទឹកទៅក្នុងដីត្រង់ណាដែលពុំសូវមានទឹកដោយការជីកប្រឡាយ ។ នេះគឺជាវិធីដែលអ្នកស្រុកអាណាចក្រភ្នំធ្លាប់តែបានអនុវត្តក្នុងការប្រកបរបរកសិកម្មរបស់ខ្លួនរួចជាយូរ ណាស់មកហើយ ។

## ខ. អំពីដើមកំណើតជាតិខ្មែរ

បញ្ហាដើមកំណើតជាតិខ្មែរនេះ មានចោទឡើងរៀងរាល់ពេលដែលគេធ្វើការសិក្សាស្រាវជ្រាវពីអរិយធម៌ឬពីប្រវត្តិសាស្ត្រខ្មែរ ។ យ៉ាងណាមិញជាតិឬពូជអំបូរជាមូលធម៌មួយយ៉ាងសំខាន់ ជួយបំភ្លឺអ្នកប្រាជ្ញក្នុងការសិក្សាស្រាវជ្រាវពីអរិយធម៌របស់ជនជាតិណាមួយ ។ ចំពោះខ្មែរយើង ការយល់មិនច្បាស់ពីអត្តសញ្ញាណ( identité) នេះហើយជាហេតុនាំអោយអ្នកសិក្សាខ្លះ មានការភ័ន្តច្រឡំ រហូតដល់ទាញភ្ជាប់ជាតិខ្មែរទៅនឹងជាតិណាមួយដែលគេយល់ថា មានអរិយធម៌ខ្ពង់ខ្ពស់ជាងខ្មែរ ។

ជាយូរយារណាស់មកហើយ អ្នកសិក្សាស្រាវជ្រាវពីខ្មែរបានខិតខំដោះស្រាយបញ្ហាដ៏សំខាន់នេះ ហើយបានបញ្ចេញជាយោបល់ឬសម្មតិកម្មប្លែកៗគ្នា ហើយជួនកាលក៏ផ្ទុយគ្នាស្រឡះតែម្តង ។ ប៉ុន្តែយើងអាចប្រមូលយោបល់ឬសម្មតិកម្មទាំងនោះបានជាបីប្រភេទ :

១. យោបល់ដែលយល់ថាខ្មែរគឺ ឥណ្ឌា ឬក៏ថាខ្មែរនិងឥណ្ឌាជាជាតិតែមួយ ។ ទស្សនៈបែបនេះលោកឧកញ៉ា ឈឹម ក្រសេម បានបញ្ជាក់យ៉ាងពិស្តារក្នុងសៀវភៅ " ពង្សាវតារ ខ្មែរភាគ១ " បោះពុម្ពនៅភ្នំពេញ គ.ស.១៩៧១ ។ លោកបានសរសេរជាអាទិថា : "តាមដែលបានស្រាវជ្រាវតាមផ្លូវ

ប្រវត្តិសាស្ត្រមកហើយ ប្រាកដថាក្នុងដែនឥណ្ឌាភាគខាងត្បូងដែលផុតអំពី មធ្យមប្រទេសជាទីតាំងប្រទេសជាច្រើននៅត្រង់រវាងកណ្តាលនៃប្រទេសទាំងនោះ គឺត្រង់ដែលហៅថា ទក្ខិណាបថឬទស្សិណាទិ្តគោលមានប្រទេសមួយឈ្មោះ "កុមេរុ "ជាប្រទេសធំមានប្រជាជនកុះករច្រើន ខ្មែរយើងដើមឡើយ មុនដែលផ្សាយមកនៅក្នុងកម្ពុជរដ្ឋ -អាស្រ័យនៅក្នុងកុមេរុរដ្ឋនោះៗជាប្រទេសរបស់ខ្មែរពីបុរាណកាលមក ។ ...ឈ្មោះជាតិខ្មែរហៅត្រឹមត្រូវតាមសូសព្ទដើមថា កុមេរុ ដូច្នេះតែតាមសំឡេងនិយាយជាធម្មតាថា កុមេរ៉ុ ទំនងដូចឈ្មោះភ្នំសុមេរុ គេហៅនៅត្រឹម សុមេរ៉ុ ។ លុះយូរមក ឈ្មោះនេះបានក្លាយចេញទៅទៀតប្រាកដនៅសិលាចារឹករបស់ខ្មែរថា "ក្មេរ " ទៅជាសំឡេងផ្សំក្រោយសម័យសិលាចារឹកមកបានប្រែថា "ខ្មែរ " ។ ...តាំងពីក្រោយពុទ្ធកាលប្រមាណ ២០០ឆ្នាំជាដើមមកជនជាតិខ្មែរបានផ្តើមផ្សាយមកក្នុងដែនសុវណ្ណភូមិ ។ ...ពួកខ្លះមកដោយប៉ងដើម្បីរកស៊ីលក់ដូរតាមធម្មតា ពួកខ្លះមកដោយរត់សឹក ។ ...អ្នកដែលនាំអារ្យធម៌ពីឥណ្ឌាមកផ្សាយក្នុង ដែនដីអោយនេះ គឺខ្មែរអាស្រ័យជាតិខ្មែរជាអ្នកមានអារ្យធម៌ខ្ពង់ខ្ពស់ទាំងមានឥទ្ធិពលទើបអាចផ្សាយអារ្យធម៌របស់ខ្លួនទៅលើជាតិទាំងឡាយដែលនៅក្រោមអំណាចនិងជាតិទាំងឡាយដែលនៅជិតខាងទៀតផង ដោយហេតុនេះទើបមានឆាយាថា "ខ្មែរជាឥណ្ឌាទី ២ "នៅក្នុងដែនសុវណ្ណភូមិ ។ ខដែលថា "ខ្មែរយើងផ្សាយមកពីឥណ្ឌា "ដូច្នេះ តើមានអ្វីខ្លះជាសំអាងតបថាក្រៅពីជាតិ និងឈ្មោះប្រទេសដូចពោលហើយ នៅមានភស្តុតាងយ៉ាងដទៃទៀតជាច្រើនយ៉ាងជាសំអាងគឺ :

ក. - លក្ខណៈអក្សរ និង ភាសារ

ខ. - លទ្ធិប្រពៃណី និងសាសនា

គ. - ពង្សាវតារ និង សេចក្តីកត់ហេតុ

...ជាតិខ្មែរនិងជាតិជ្វា ជាម្ចាស់ស្រុកដើម បានរួមគ្នាទៅជាជាតិមួយហៅថា កុមេរុ គឺជាខ្មែរសព្វថ្ងៃនេះ ។...ខ្មែរក្នុងជាន់ដើមរូបរាងច្រើនស្រងៗច្រមុះស្រួច សំបុរ កាយខ្មៅស្រអែម ...ឯជាតិជ្វានោះមានលក្ខណៈរូបរាងជាយ៉ាងមធ្យម សំបុរកាយសជ្រះ រូបច្រើនល្អ ។...ពង្សាវតារភូមាថា **មន** និង **ខ្មែរ** ជាបងប្អូនផងគ្នាចុះមកអំពីឥណ្ឌាទាំងពីរពួក តែពួក **មន** ផ្សាយមកមុនបន្តិច ។

ទស្សនៈរបស់លោកឧកញ៉ា ឈឹម ក្រសេម ខាងលើនេះ មានជនបរទេសយល់ស្របតាម និងយកទៅប្រើប្រាស់ជាផលប្រយោជន៍របស់គេថែមទៀត ។ លោក Pierre Loti អ្នកនិពន្ធបារាំងដ៏ល្បីល្បាញមួយរូប បានសរសេរក្នុងសៀវភៅឈ្មោះPèlerin d´Ang kor ថា : " le peuplekhmer¸ rameau détaché de la grande race aryenne... "( ប្រជារាស្ត្រខ្មែរជាមែកធាងដែលដាច់ចេញពីមហាអំបូអារ្យ ...) ។ ចំណែកលោកមុំសេនីប្រាមោជ មេធាវីថៃអមតុលាកាអន្តរជាតិ នាទីក្រុងឡាអេ

(La Hye) បានលើកយកទស្សនៈបែបនេះមកធ្វើជាទឡ្ហីករ ដើម្បីប្រឆាំងនឹងខ្មែរយើងក្នុងរឿងក្តីប្រាសាទព្រះវិហារ ហើយដែលសារពត៌មានសៀមឈ្មោះ "ឆាវថៃ" ចុះថ្ងៃទី ៣១ ខែតុលា ១៩៥៩ បានរំលឹកថា : " មុំសេនីប្រាមោជបាននិយាយថា ពពួក "**ខម**" ជាជនពូជអំបូរឥណ្ឌា ។ ជនជាតិថៃមានដើមកំនើតក្នុងខេត្តចិនយូនណានបានវាយយកជោគជ័យទៅលើជាតិខម រហូតដល់ពួកនេះត្រឡប់ទៅស្រុកឥណ្ឌាវិញ ។ ដែនដីដែលពីដើមពួកខម តាំងនៅក៏ក្លាយទៅជាដីថៃ ហើយប្រជាជនថៃក៏បែងចែកខ្លួនឯងជាពីរក្រុម ។ ក្រុមទី១ មកតាំងនៅតំបន់ទំនាប ដែលគេអោយឈ្មោះសព្វថ្ងៃថា "**កម្ពុជា**" ។ ក្រុមមួយទៀតបានតាំងនៅតំបន់ខ្ពស់ ហើយនៅថែរក្សាឈ្មោះថៃដដែល " ។

២- យោបល់ដែលចាត់ទុកជាតិខ្មែរជាជាតិប្រវេសន៍ ចេញពីប្រទេសឥណ្ឌាហើយបានមកលុកលុយដណ្តើមយកទឹកដីរបស់ជាតិដើមមួយគឺ ជនជាតិក្នុងអំបូរម៉ាឡាយូ-ប៉ូលីនេស៊ីយែនឬជនជាតិថៃ-កាដៃ ប៉ុន្តែជាជាតិមួយដោយឡែកពីជាតិឥណ្ឌា ហើយស្ថិតក្នុងអំបូរមន-ខ្មែរ ។ នេះជាទស្សនៈរបស់លោក Henkrik kern លោក Adhémard Lecléré (១) ។ លោក paul Benedict លោក Pierre Gourou ។ ចំពោះទស្សនៈនេះលោក PierreGourou បានបញ្ជាក់ថា ជនជាតិមន-ខ្មែរប្រហែលជា ត្រូវពួកទ្រាវិឌឬពួកអារ្យច្រានចេញពីប្រទេសឥណ្ឌាហើយដោយមាននៅសល់ក្រុមខ្លះដូចជាពួកមុណ្ឌបានមកលុកលុយប្រទេសភូមា ប្រទេសសៀម និងប្រទេសកម្ពុជា ។

គេអាចបន្ថែមទៅក្នុងក្រុមអ្នកស្រាវជ្រាវទី២ នូវឈ្មោះលោក Etienne Aymonier ដែលយល់ថាក្រុមមន-ខ្មែរ-មុណ្ឌ មានទីតាំងដើមនៅជើងភ្នំទីបេហើយក្រោយមកបានបំបែកជាពីរក្រុម : មួយក្រុម(មន-ខ្មែរ) ចូលមករស់នៅក្នុងភូមិភាគអាស៊ីអគ្នេយ៍ ឯមួយក្រុមទៀត(មុណ្ឌ) ចូលទៅនៅក្នុងប្រទេសឥណ្ឌារហូតដល់សព្វថ្ងៃ (៣) ។

៣- យោបល់ដែលទទួលស្គាល់ថា ជាតិខ្មែរជាជាតិពិសេសមួយស្ថិតនៅក្នុងអំបូរ **មន-ខ្មែរ** ហើយបានកកើតឡើងនៅភូមិភាគអាស៊ីអាគ្នេយ៍នេះតែម្តង ។ នេះគឺជាទស្សនៈរបស់លោក Berard Philippe Groslier (4) និង លោក Marcel Talabot ជាដើម ។ លោកទាំងពីរនេះយល់ឃើញថាក្នុងសម័យ បុព្វប្រវត្តិសាស្ត្រដ៏យូរលង់ណាស់មកហើយមានមនុស្សពូជខុសៗគ្នាបានធ្វើដំណើរពីខាងជើងចុះមក

អាស៊ីអគ្នេយ៍ ហើយផ្សំកាត់ជាមួយគ្នា ។ តាមការប៉ាន់ស្មានរបស់លោកទាំងពីរ អំបូរ **មន ខ្មែរ** យើងកើតមកពីការផ្សំកាត់រវាងពូជមេឡាណេស៊ីយាង(Mé lanésiens) និងពូជ **ឥណ្ឌូណេស៊ីយាង** (Indonésiens) ហើយបានរស់នៅលើទឹកដីលាតសន្ធឹងពីឆ្នេរសមុទ្រចិន រហូតដល់ព្រំប្រទល់ប្រទេសឥណ្ឌា ។

---

១.២.៣. ជាលេខយោងទៅឯកសារពិគ្រោះដែលមានចុះក្នុងបញ្ជីនៅខាងចុងសៀវភៅនេះ ។

រួចមកហើយ ឃើញបានលាតត្រដាងនូវយោបល់និងសម្មតិកម្មរបស់អ្នកសិក្សាស្រាវជ្រាវពីជាតិខ្មែរ ។ ឃើញថាយោបល់និងសម្មតិកម្មទាំងនោះទោះបីប្លែកគ្នា ក៏បានស្របគ្នាត្រង់ចំណុចដែលថាខ្មែរនិងមនស្ថិតនៅក្នុងអំបូរជាមួយគ្នា គឺអំបូរមនខ្មែរនេះឯង ។ ដូច្នេះ តទៅនេះយើងនឹងខិតខំរែកញែករកមើលថាតើមន ខ្មែរនេះជាអំបូរមួយពិសេសឬក៏ជាជាតិឥណ្ឌាដែរ ?

បើតាមទស្សនៈរបស់លោកឧកញ៉ា ឈឹម ក្រសេម ឃើញថា ខ្មែរគឺជាឥណ្ឌាហ្នឹងឯង ព្រោះបានចេញមកពីប្រទេសឥណ្ឌាមានឈ្មោះជាឥណ្ឌា មានទំនៀមទំលាប់ សាសនា អក្សរ ភាសា ជារបស់ឥណ្ឌា ហើយមនុស្សខ្មែរដើមទៀតសោតក៏មាន លក្ខណៈជាឥណ្ឌាបេះបិទ ហើយលោកបានបញ្ជាក់ថាខ្មែរជា **ឥណ្ឌាទី ២** ។

ប្រសិនបើយើងលើកយកលទ្ធផលនៃការស្រាវជ្រាវរបស់នរវិទូក្នុងពិភពលោកមកពិនិត្យមើលឃើញថា មនុស្សខ្មែរនិងមនុស្សឥណ្ឌា(ទាំងពួកសទាំងពួកខ្មៅ )មានលក្ខណៈខុសគ្នាឆ្ងាយណាស់ ។ យ៉ាងណាមិញខ្មែរមានកំពស់ជាមធ្យម១ , ៦១ម. និងសន្ទស្សន៍លលាដ៏ក្បាល ៨៤ , ៥(ក្បាលមូល) ចំណែកឯពួកឥណ្ឌា-ស(អារ្យ)មានកំពស់ ១,៧២ម.និងសន្ទស្សន៍លលាដ៏ក្បាល៧៣,៨(ក្បាលពយ) និងពួកឥណ្ឌាខ្មៅ(ទ្រាវិឌ)មានកំពស់១,៦២ម.និងសន្ទទស្សន៍លលាដ៏ក្បាល ៧៦,២(ក្បាលពយទៀត) (៥) ។ ឯការដែលអះអាងថាខ្មែរចេញពីប្រទេសឥណ្ឌានោះតើមានអ្វីអាចបញ្ជាក់បាន ? ត្រង់ទំនៀមទំលាប់ សាសនា អក្សរភាសា ក្នុងផ្នែកនេះ ខ្មែរយើងបានទទួលឥទ្ធិពលពីឥណ្ឌាក៏ពិតមែន ប៉ុន្តែការសិក្សាជីកដល់ជំរៅបានបង្ហាញអោយឃើញថា ខ្មែរយើងមានអរិយធម៌ផ្ទាល់របស់ខ្លួនទៅហើយមុនដែលបានទាក់ទងជាមួយឥណ្ឌា ។ បានសេចក្តីថា ខ្មែរជាពូជដោយឡែកពីឥណ្ឌា នេះហើយជាទស្សនៈរបស់ក្រុមអ្នកស្រាវជ្រាវទី ៣ដែលយល់ថាអំបូរខ្មែរមន បានកកើតឡើងនៅត្រង់ភូមិភាគអាស៊ីអគ្នេយ៍នេះតែម្តង ដោយការផ្សំកាត់រវាងពួក មេឡាណេស៊ីយាង (កំពស់ពី ១,៦៥ម ក្បាលពយ)និងពួកឥណ្ឌូណេស៊ីយាង(កំពស់ពី១ , ៦០ម.ទៅ១,៦៣ម.ក្បាលមូល) ។ គួរកត់សំគាល់ថាទស្សនៈនេះមានលក្ខណៈស្របនឹងទស្សនៈរបស់ខ្មែរដែរ ពីព្រោះបើយើងសំអាងទៅលើរឿងព្រេងខ្មែរក៏ដោយ លុះត្រាតែមាន**នាងនាគ**នៅស្រុកខ្មែរនេះឯង ទើប **ព្រះថោង** (ដែលគេថាមកពីស្រុកឥណ្ឌា)បានជួបប្រភពគ្នាដោយបានគ្រប់គ្រងស្រុកគោកធ្លកនេះដែរ ។ បានសេចក្តីថា លុះត្រាតែមានជាតិខ្មែរនៅលើកោះគោកធ្លកនេះដែរ ទើបឥណ្ឌាអាចផ្សាយអរិយធម៌របស់ខ្លួនបានខ្លះចូលក្នុងស្រុកខ្មែរ ។ និយាយពីដើមកំណើតជាតិខ្មែរនេះដែរ លោក Maurice Glaizer អតីតអភិរក្សអង្គរ បានសរសេរជាអាទិថា : “Ce n’est nullement,comme certains le croient,un peuple d’origine puremen tindinne qui ser ait venu,à la suite de migrations,se fixer dans une région vide d’habitants, ou en aurait éliminé les eléments indigènes par des massacres ou des déportations en masse : les

peuple khmer est un peuple autochtone hindouisé "(មិនមែនដូចអ្នកខ្លះបានយល់នោះទេ ថាជាប្រជារាស្ត្រមួយដែលមានដើមកំណើតជាឥណ្ឌាសុទ្ធសាធហើយដែលបានមកតាំងនៅក្នុងតំបន់មួយគ្មានមនុស្សឬក៏បានកំចាត់ពួកអ្នកស្រុកអោយដោយការសម្លាប់រង្គាលឬការនិរទេសទាំងហ្វូង : ប្រជារាស្ត្រខ្មែរ គឺជាអ្នកស្រុកដើមដែលបានទទួលឥទ្ធិពលអរិយធម៌ឥណ្ឌា )[៦] ។

ឯលោក Henri Marchal អតីតអភិរក្សអង្គរដែរ បានសរសេរថា : " le Cambodgien n'est pes de race hindoue, il est le résultat de nombreux croisements avec un fond malayo-indonésien..." (ខ្មែរមិនមែនជាមនុស្សពូជសាសន៍ឥណ្ឌាទេ : ខ្មែរជាលទ្ធផលនៃការផ្សំកាត់ច្រើនជាមួយនឹងមលយូ-ឥណ្ឌូណេស៊ីយាង... )[៧] ។

ចំពោះយោបល់ដែលថា ខ្មែរបានមកលុកលុយដណ្តើមយកទឹកដីរបស់ជនជាតិដើមមួយនោះ ច្រើនតែសំអាងទៅលើរឿងព្រេងខ្មែរដែលបាននិទានថា មានស្តេចចាមមួយអង្គ បាននាំបរិវារ៥០០ នាក់ជិះសំពៅកំសាន្តតាមមហាសាគរ លុះប៉ះនឹងខ្យល់ព្យុះបោកបក់មកនាំអោយវិនាសសំពៅអស់ទៅ ក៏រសាត់ទៅដល់កោះគោកធ្លក ហើយបានរស់នៅទីនោះតទៅ ។ តាមយោបល់យើង ការដែលថា ជ្វាឬចាមជាម្ចាស់ដើមនៃស្រុកគោកធ្លកដូចជាមិនទំនង ព្រោះពួកនោះជាអ្នកចំណូលថ្មីបានជិះសំពៅមកពីស្រុករបស់គេ(មិនដឹងច្បាស់ថានៅទីណាទេ តែបើតាមប៉ាន់ស្មានមើលប្រហែលមកពីម្តុំខ្ពង់រាបខ្ពស់ប្រទេសវៀតណាមសព្វថ្ងៃ មិនមែនមកពីប្រទេសឥណ្ឌូនេស៊ី ព្រោះចរន្តច្រើនចុះពីជើងទៅត្បូង) ។ តាមសេចក្តីដំណាលរបស់រឿងព្រេងដដែលឃើញថា **ព្រះថោង** បានមករៀបការជាមួយនាង **នាគី** ដែលរស់នៅទីនោះមុនការមកដល់នៃពួកចាមនិងព្រះថោងទៅទៀត ។ បើដូច្នេះ តើយើងចាត់ទុកថា-នាងនាគីនេះជាអ្វី ? ជាសត្វតិរច្ឆានមែនឬក៏ជាមនុស្សដើមបង្អស់នៅទីនោះ(នាងចេះកាឡាខ្លួនជាមនុស្សមានរូបរាងល្អ ) ។

រួមសេចក្តីមក ឃើញថាមានភស្តុតាងជាច្រើនបង្ហាញថា ខ្មែរជាជាតិមានចំណាស់បានកកើតឡើងនៅភូមិភាគអាស៊ីអគ្នេយ៍នេះ ហើយស្ថិតនៅក្នុងអំបូរមនុស្សមួយដោយឡែកពីអំបូរឥណ្ឌាហើយដែលនរវិទូលោកអោយឈ្មោះថា **អូស្ត្រូអាស្យាទិក** (Au stroasiatiques) ។ ជាតិខ្មែរបានកកើតឡើងបានវិវត្តហើយមានជីវិតស្ថិតស្ថេរហូតមកដល់សព្វថ្ងៃនៅលើទឹកដីដែលដូនតាខ្លួនបានកសាងទុកជាកេរដំណែល ។ ចំណែកជនជាតិដទៃទៀត ដែលបានមករស់នៅ នៅភូមិភាគអាស៊ីអគ្នេយ៍ដីគោកសព្វថ្ងៃជាអ្នកជិតខាងរបស់ខ្មែរ គឺសុទ្ធតែបានមកដល់ក្រោយ(លើកលែងតែជនជាតិចាមចេញ)គឺថា បានចូលមកក្នុងសម័យប្រវត្តិសាស្ត្រដែលគេអាចដឹងបានច្បាស់លាស់តាមឯកសារផ្សេងៗ : ភូមា (ស.វ.ទី ៩) យួន (ស.វ.១០) សៀម(ស.វ.ទី១៣) ។

# ជំពូក ២

# អំពីអំបូរខ្មែរ-មន

កាលពីដើមអំបូរខ្មែរ **ខ្មែរ-មន** នេះគេយល់ថា គ្រាន់តែជាអំបូរភាសាមួយប៉ុណ្ណោះ ។ យ៉ាងណាមិញ ភាសាវិទូមួយក្រុមមានជាអាទិលោក James R .Logan បានរកឃើញនូវអត្ថិភាពនៃអំបូរភាសានេះមុនគេនៅឆ្នាំ១៨៥៦ប៉ុន្តែកាលណោះគេនិយមហៅអំបូរនេះថា **មន-អាណ្ណាម** ឬ **មន-ខ្មែរ=អាណ្ណាម** ។ ក្រោយមកទៀត ដោយសិក្សាទៅឃើញថាភាសាអាណ្ណាមមានលក្ខណៈខុសប្លែកពីអំបូរភាសាមន = ខ្មែរ ទើបភាសាវិទូខ្លះបានដកភាសានេះចេញ ហើយយកទៅបញ្ចូលក្នុងក្រុមភាសាថៃវិញ ។ នេះជាទស្សនៈរបស់លោក Henri Maspéro ដែលលោកបានលាតត្រដាងយ៉ាងច្បាស់លាស់ក្នុងអត្ថបទសិក្សាមួយមានចំណងជើងថា “Etude Sur La phonétique historique de La langue annamite..Les initiales . ” ។

ចំពោះភាសាវិទូជាតិអាល្លឺម៉ង់ P. W. Schmidt អំបូរ **មន-ខ្មែរ** មិនគ្រាន់តែជាអំបូរភាសាទេ តែជាអំបូរជាតិសាសន៍ផងដែរ ។ ក្នុងសៀវភៅ “ Les peuples mon-Khmer ” បោះពុម្ពផ្សាយនៅឆ្នាំ ១៩០៨ នៅហាណូយលោកបានបង្ហាញនូវលក្ខណៈរូបរាងកាយរបស់ជនជាតិទាំងនោះដែលមានដូចតទៅ :

- មាឌតូចល្មម អាចឡើងដល់មធ្យម
- ស្បែកសម្បុរសណ្តែកបាយ (Foncé)
- ភ្នែកមានសណ្ឋានត្រង់ហើយផ្តេក បើកធំៗ
- ច្រមុះទូលាយ
- ក្បាលពយ

គួរកត់សំគាល់ថា ចំពោះមាឌក្តី លលាដ៏ក្បាលក្តីលោក P. W. Schmidt ពុំបានបង្ហាញលេខក្នុងការវាស់វែងអោយបានច្បាស់លាស់ទេ ហើយមានចំនុចខ្លះដូចជាលលាដ៏ក្បាលជាដើម លោកបានបង្ហាញលទ្ធផលដែលមានទំនាស់នឹងលទ្ធផលផ្តល់ដោយអ្នកប្រាជ្ញផ្សេងទៀត ។ ក្នុងសៀវភៅមានចំណងជើងថា "Les populations du Cambodge" លោកបណ្ឌិត G .Olivier បានចុះផ្សាយនូវតារាងនៃលទ្ធផល ការវាស់វែងរបស់លោក ហើយដែលយើងអាចដកស្រង់បានដូចតទៅ ៖

- ខ្មែរមានកំពស់ជាមធ្យម ១,៦១ម. និងសន្ទស្សន៍លលាដ៏ក្បាល ៨៤,៥
- មនមានកំពស់ជាមធ្យម ១,៦២ម. និងសន្ទស្សន៍លលាដ៏ក្បាល ៨៥,៦

បើយោលតាមលទ្ធផលខាងលើនេះយើងឃើញថា ខ្មែរ និងមនមានកំពស់មធ្យមដូចគ្នា (ខុសគ្នាតែ១ភាគរយប៉ុណ្ណោះ) ឯក្បាលក៏មូលដូចគ្នាទៀត (ខុសគ្នាតែ១,១) មិនមែនពយដូចលោក P. W. Schmidt យល់នោះទេ ។ ប៉ុន្តែទោះជាយ៉ាងនេះក៏ដោយ ក៏យើងអាចយល់ថាត្រង់ហ្នឹងគ្រាន់តែជាការភ័ន្តច្រឡំទេ ព្រោះលោកបានសរសេរសន្និដ្ឋានថា លក្ខណៈទាំងនោះអនុញ្ញាតអោយលោកអះអាងថាពួកមនុស្សនោះស្ថិតដាច់ចេញពីអំបូរមុងហ្គោលផង និងពីអំបូរអារ្យផង ។

លោក Maurice Glaize អតីតអភិរក្សអង្គរ បានសរសេរក្នុងសៀវភៅ " Les monuments du groupe d'Angkor" ថា "...les Khmers se rattachent en effet , tant au point de vue eth nologique quelinguistique ,aux populations môn de Basse Birmanie....." (ជនជាតិខ្មែរជាប់ពូជអំបូរទាំងខាងជាតិសាសន៍និងទាំងខាងភាសាទៅនឹងជនជាតិមននេះប្រទេសភូមាខាងក្រោម) ។ ឯលោក Pilippe Devillers អ្នកស្រាវជ្រាវបារាំងម្នាក់ទៀត បានសរសេរក្នុងសៀវភៅ L'Asie du SudEst ក្បាលទី២ ថា «...khmers,peuple de même souche ethnolinguistique que les Môns» ... (ខ្មែរជាជនជាតិដែលមានឫសគល់ខាងជាតិសាសន៍ និងភាសាជាមួយនឹងជនជាតិមន) ។

សរុបសេចក្តីមក យើងឃើញថាលទ្ធផលនៃការសិក្សាស្រាវជ្រាវរបស់លោក P .W .schmidt លោក G. Olivier លោក Maurice Glaize និងលោក Philippe Devillers ដូចបានរៀបរាប់រួចមក ហើយជាភស្តុតាងសំរាប់បញ្ជាក់និងគាំទ្រនូវទស្សនៈរបស់លោកអ្នកប្រាជ្ញទាំងឡាយ ដែលបានចាត់ទុកជាអំបូរ **ខ្មែរ-មន** ជាអំបូរពិសេសមួយ ។

បើតាមឯកសារថ្មីដែលបោះពុម្ពផ្សាយនៅសហរដ្ឋអាមេរិកនៅឆ្នាំ១៩៦៤ (Ethnic groups of mainland south-East Asia) អំបូរខ្មែរ=មន មានគ្នាទាំងអស់ ៧៦ក្រុមរស់នៅចាប់ពីប្រទេសឥណ្ឌាភាគខាងកើត រហូតដល់សមុទ្រចិនដោយកាត់តាមប្រទេស ភូមា ប្រទេសថៃ ប្រទេសលាវ ប្រទេសវៀតណាម និងសាធារណរដ្ឋខ្មែរ ។ ក្នុងចំណោមជនជាតិខ្មែរ-មនទាំងឡាយ មានតែខ្មែរនិងមនទេ

ដែលបានក៏សាងអរិយធម៌ ខ្ពង់ខ្ពស់ជាងគេ ព្រោះម្យ៉ាងដោយហេតុជនជាតិទាំងនេះបានទៅរស់នៅត្រង់វាលទំនាបនៃទន្លេធំៗដែលមានដីជាតិល្អ ហើយម្យ៉ាងទៀតដោយមានការប្រាស្រ័យទាក់ទងនឹងជនបរទេសទៀតផង ។ ចំណែកឯជនជាតិខ្មែរ-មនឯទៀតដែលរស់នៅតាមព្រៃ-ភ្នំ ស្ទើរតែគ្មានទំនាក់ទំនងជាមួយគ្នាផងនោះក៏ឃើញថាគ្មានការចំរើនលូតលាស់ នៅទន់ខ្សោយតែគ្រប់វិស័យទាំងអស់ ។ ដោយហេតុនេះហើយបានជាអ្នកប្រាជ្ញលោកបានយកឈ្មោះពីរនេះ គឺ **មន** និង **ខ្មែរ** មកធ្វើជាឈ្មោះសំរាប់សំគាល់អំបូរទាំងមូល គឺអំបូរខ្មែរមន ប៉ុន្តែខ្មែរយើងបានផ្លាស់ឈ្មោះនេះពី **មន = ខ្មែរ** មកជាខ្មែរ-មនវិញ ព្រោះយើងយល់ថា ខ្មែរជាធាតុសំខាន់ជាងគេ ព្រោះជាជនជាតិមួយមានគ្នាច្រើនជាងគេ ហើយមានឋានៈជារដ្ឋប្រកបដោយឯករាជ្យ អធិបតេយ្យ និងអរិយធម៌ខ្ពង់ខ្ពស់ទៀតផង ។ គួរបញ្ជាក់ដែលថា ការកែប្រែរួចមកហើយនេះ បានទទួលការយល់ព្រមពីអង្គការយូណេស្កូ ក្នុងសម័យប្រជុំកាលពីខែតុលា-វិច្ឆិកាឆ្នាំ១៩៧០ហើយ ។

តទៅនេះ យើងសូមលើកយកធាតុសំខាន់ជាងគេពីរនៃអំបូរខ្មែរ-មនមកសិក្សាដើម្បីអោយបានដឹងថា តើខ្មែរនិងមននេះជាអ្វី ?

## ក. ខ្មែរ

ក្នុងការសិក្សាស្រាវជ្រាវពីខ្មែរ ទោះក្នុងផ្នែកជាតិសាសន៍ក្តី ក្នុងផ្នែកប្រវត្តិសាស្ត្រក្តី ក្នុងផ្នែកវប្បធម៌-អរិយធម៌ក្តី គេតែងឃើញមានបញ្ហាចោទឡើងចំពោះពាក្យថា **ខ្មែរ-មន-កម្ពុជា** នេះឯង ។ ចំពោះពាក្យទាំងបីខាងលើនេះ អ្នកសិក្សាស្រាវជ្រាវបានផ្តល់យោបល់ច្រើនបែបច្រើនយ៉ាងណាស់ ។ រហូតដល់ពេលនេះ យើងមិនទាន់ហ៊ានសន្និដ្ឋានថា យោបល់ណាត្រឹមត្រូវជាងយោបល់ណាទេ ។ ដើម្បីជាការត្រិះរិះសំរាប់អ្នកសិក្សា យើងសូមលើកយកទស្សនៈទាំងនោះ មកលាតត្រដាងមួយម្តងៗដូចតទៅនេះ :

### ១. ទស្សនៈលោក G .Coedès

អ្នកប្រាជ្ញរូបនេះបានយល់ថាពាក្យ **ខ្មែរ**ប្រហែលជាកើតមកពីការផ្សំរវាងឈ្មោះ**កម្ពុ** និង **មេរា** ដោយសំអាងទៅលើរឿងព្រេងក្នុងសិលាចារឹក បក្សីចាំក្រុង(ស.វ.ទី១០)ដែលបាននិទានថា ស្តេចខ្មែរយើងមានដើមកំណើតមកពី ឥសី **កម្ពុស្វយម្ភុវ** និងនាងទេពអប្សរ **មេរា** ដែលព្រះឥសូរបានប្រទានអោយជាមហេសី ។ ទស្សនៈបែបនេះលោក G.Coedès បានលាតត្រដាងក្នុងស្នាដៃរបស់លោកឈ្មោះ Histoire ancienne des Etats Hindouisés d’Extrême-Orient បោះពុម្ពផ្សាយនៅក្រុងប៉ា-

ណូយកាលពីឆ្នាំ១៩៤៤ ហើយត្រូវបានព្រះភិក្ខុវីរិយបណ្ឌិតោ **ង៉ោខ ខាត់**យល់ស្របតាមទាំងស្រុង ។ នៅក្នុងទស្សនាវដ្ដីពុទ្ធិកសិក្សាឆ្នាំទី១ លេខ៥ ឆ្នាំ១៩៥៧ ព្រះអង្គបានសរសេរជាអាទិថាៈ “ការសម្ព័ន្ធឫសីកម្ពុ និងនាង**មេរា** នេះជាបុព្វហេតុដែលនាំអោយកើតជាសូរ្យវង្ស ឬអាទិច្ចវង្សឡើងនៅខាងចេនឡា ។ បើយើងអានព្រមៀលពាក្យ **កម្ពុ មេរា**នេះបន្តិចម្តងៗក៏នឹងបានទៅជាពាក្យខ្មែរដូច **កម្ពុ+មេរា › កម្ពុ +មេរ› កម្ព + មេរ › កំម + មេរ › ក មេរ › ក្មេរ - ខ្មែរ** ។ ដំណើរនេះមានន័យសមរម្យទំនងបានទៅជាពាក្យថាខ្មែរណាស់ ។ ...អ្នកបាលីបានធ្វើពាក្យថា **ខ្មែរ**ទៅជាបាលីថា **ខេមរ** ប្រែថា “អ្នកមានសេចក្តីក្សេមក្សាន្ត ” ។

ពាក្យថា **កម្ពុជា** ក៏កើតចេញមកពីពាក្យឫសី **កម្ពុ (+ស្វយម្ភូវ)** នេះដែរ ព្រោះកាលដែលឫសី **កម្ពុ** បាននាងអប្សរ **មេរា**នោះ ក៏បានកើតទៅជាវង្សមួយខាងចេនឡា ហៅថា សូរ្យវង្សឬអាទិច្ចវង្សគឺវង្សស្រីកម្ពុ ។ តាមប្រវត្តិថា ការសម្ព័ន្ធ **កម្ពុ មេរា** នេះកើតបានជាបុត្រពីរអង្គហៅថា **កម្ពុជៈ** = បុត្រកម្ពុគឺស្រុកវរ្ម័ន និងស្រេស្ធវរ្ម័ន សោយរាជ្យតសន្តតិវង្សខាងចេនឡាជាប់រៀងដរាបមក ។ ដើមឡើយគេមិនសូវឃើញមានប្រើពាក្យ **កម្ពុជៈ** នេះទេ តែការព្រះបាទជ័យវរ្ម័នទី២ បានសោយរាជ្យមានអំណាចខ្លាំងពូកែ បានរួបរួមចេនឡាលើក្រោមអោយជាឯកភាព ហើយទើបឃើញមានសិលាចារឹកប្រើពាក្យថា **កម្វុជទេស** ឬ **កម្ពុជទេស :** ប្រទេសនៃបុត្រកម្ពុ ។

ចំពោះយោបល់ដែលថាពាក្យ **ខ្មែរ** កើតមកពីការផ្សំ **កម្ពុ** និង **មេរា** លោកឆត្រាប្រេមឬឌី និងលោក Pierre Fabricius ថាមិនសមហេតុផលទេ ព្រោះមិនស្របតាមក្បួនច្បាប់និរុត្តិវិជ្ជា ។

## ២. ទស្សនៈលោក ឈឹម ក្រសេម

នៅក្នុងជំពូកទី១ ស្តីពីដើមកំណើតជាតិខ្មែរ យើងមានឱកាសលើកយកទស្សនៈនេះមកលាតត្រដាងម្តងរួចមកហើយ ។ នៅពេលនេះយើងគ្រាន់តែស្រង់យកអន្លើខ្លះបង្ហាញឡើងវិញ សំរាប់បំភ្លឺនូវការសិក្សារបស់យើងតែប៉ុណ្ណោះ ។ លោក ឈឹម ក្រសេម បានសរសេរជាអាទិថា “...ខ្មែរយើងដើមឡើយមុនដែលផ្សាយមកនៅក្នុងកម្ពុជរដ្ឋ- អាស្រ័យនៅក្នុងកុមេរុរដ្ឋនោះៗជាប្រទេសរបស់ខ្មែរ អំពីបុរាណកាលមក ។... ឈ្មោះជាតិខ្មែរហៅត្រឹមត្រូវតាមសូរសព្ទដើមថា **កុមេរុ** ដូច្នេះតែតាមសំឡេងនិយាយជាធម្មតាថា កុមេរ៉ុ ទំនងដូចឈ្មោះភ្នំព្រះសុមេរុគេហៅនៅត្រឹមសុមេរ៉ុ ។ លុះយូរមកឈ្មោះនេះបានក្លាយចេញទៅទៀត ប្រាកដនៅសិលាចារឹករបស់ខ្មែរថា **ក្មេរ** ទៅជាសំឡេងផ្សំក្រោយសម័យសិលាចារឹកមកបានប្រែថា **ខ្មែរ** ។

ដូច្នេះ បើតាមលោកឈឹម ក្រសេមពាក្យ **ខ្មែរ** បានក្លាយមកពីពាក្យ **ក្មេរ**ដែលជាឈ្មោះសំគាល់ជនជាតិខ្មែរ និងប្រទេសរបស់ខ្លួនកាលដែលរស់នៅក្នុងប្រទេសឥណ្ឌាម្ល៉េះ ។ លោកឆត្រាប្រេមឬឱ ក្នុងអត្ថបទ "**ខ្មែរ**មកពីណា? "ផ្សាយតាមវិទ្យុជាតិនៅខែ កុម្ភៈ១៩៧៣ បានគាំទ្រទស្សនៈនេះយ៉ាងសកម្មណាស់ ។

**ក្មេរ › ក្មែរ › ខ្មែរ**

## ៣. ទស្សនៈលោក រស់សារេត

ក្នុងអត្ថបទស្នើសុំធ្វើវិសោធនកម្មផ្ញើរជូនសភាធម្មនុញ្ញហើយដែលចុះថ្ងៃទី១៦ខែ ធ្នូ ឆ្នាំ១៩៧១ លោករស់ សារេត សមាជិកនៃអង្គការជាន់ខ្ពស់នេះ បានសរសេរជាអាទិថា : "បើតាមការសិក្សាស្រាវជ្រាវដែលខ្ញុំធ្លាប់បានពិចារណាចេះចាំមក ឃើញថាប្រទេសខ្មែរដែលការពីជំនាន់ ហៅថា **ក្រុង ខម** នោះគឺជាតួដែនដីឬឧបទ្វីប **សុវណ្ណភូមិ** ដែលភាសាបារាំងហៅថា La Chersonèse d'or... ការដែលយើងយកន័យខាងលើនេះមកពោលគឺគ្រាន់តែចង់បង្ហាញអោយឃើញថា **សុវណ្ណភូមិ** គឺជា **នគរខម** ឬហៅថា **ក្រុងខម**ដែលមានន័យថា មាសដូចគ្នា។ ពាក្យថា **ខម**នេះក្លាយមកពីពាក្យថា **កម** ដែលប្រែថា **មាស** ។ ឯស្តេចដែលសោយរាជ្យបឋមវង្សនៃនគរ ខម មានព្រះនាមថា : **កមេរុរាជ**ដែលប្រែថា **មាស**ដែរ ហើយដែលត្រូវនឹងភាសាសៀមថា **ព្រះថង** រួចដែលក្លាយយារទៅជា **ព្រះថោង** ដូចដែលយើងធ្លាប់ថារត់មាត់មកហើយ ។

ហេតុអ្វីបានជាជនជាតិខមប្រែក្លាយទៅឈ្មោះថា **ខ្មែរ** ទៅវិញ ? ត្រង់ណេះប្រហែលមកពីជនជាតិខម នៅពេលចំណេរចេរកាលតមកក្រោយទៀត ចង់រក្សាតម្លៃឥទ្ធិរិទ្ធិរបស់ខ្លួនដែលធ្លាប់ល្បីល្បាញខ្លាំងពូកែ កាលពីជំនាន់កមេរុរាជ ជាក្សត្របឋមវង្សគ្រប់គ្រងក្រុង ខម នោះហើយ បានជាប្រែក្លាយឈ្មោះពី **កម** ឬ **ខម** មកជា **កមេរុ** ឬ **ខមេរុ** ហើយដែលយារយូរៗមកទៅជា ក្មេរ រួចទីបំផុតទៅជាខ្មែរសព្វថ្ងៃនេះ ។

ចុះចំណែកពាក្យថា **កម្ពុជា** វិញយ៉ាងមេចដែរ ? បើយើងបានពិចារណានូវសម្មតិកម្មពីខាងលើនេះរួចហើយ យើងប្រហែលជាអាចយល់បានដោយងាយអំពីន័យនៃឈ្មោះថា **កម្ពុជា** នេះ។ នៅក្នុងពាក្យថា **កម្ពុជា**យើងឃើញមានពាក្យ **កម**ដែលប្រែថាមាស ហើយនិងពាក្យ ពុជា ដែលប្រែថា **ពូជ** ផ្សំគ្នាទៅជា **កម្ពុជា** គឺ**កម** ឬ **ខម** ឬ **ក្មែរ** ឬ **ខ្មែរ** ដដែលហ្នឹងឯង ។

សរុបសេចក្តីមក យើងអាចសង្ខេបទស្សនៈរបស់លោក **រស់ សារេត** ក្នុងតារាងខាងក្រោមនេះ

**កម › ខម › កមេរុ › ខមេរុ › ក្មែរ › ខ្មែរ › កម + ពុជា › កម្ពុជា** ។

## ៤. ទស្សនៈរបស់លោក ពៅ ឈិន

លោកពៅ ឈិន ជាព្រឹទ្ធបុរសនៃក្រុមសាលាសន្សំសុខ សង្កាត់លេខ៥ក្រុងភ្នំពេញបានសរសេរក្នុងសៀវភៅ "អរិយធម៌ខ្មែរ-មន "បោះពុម្ពនៅចុងឆ្នាំ១៩៧១ថា : "ពាក្យថា ខ្មែរ ក្នុងវចនានុក្រមសម្ដេចព្រះសង្ឃរាជ **ជួន ណាត** ព្រះអង្គទ្រង់បានប្រាប់ថា នៅក្នុងអក្សរសិលាចារឹកពីបុរាណឃើញមានសរសេរ **ក្មែរ**យ៉ាងនេះខ្លះដែរ ប៉ុន្តែព្រះអង្គទ្រង់យល់ថា ពាក្យនេះទំនងមកពីមគធភាសាថា **ខេមរៈ** ដែលប្រែថា "មនុស្សមានសេចក្ដីក្សេម "ដោយសម្រេចរូបមកពីអត្ថិតទ្ធិតថា "ខេមំ-យស្ស-អត្ថិតិ-ខេមរោ " ។

មួយទៀតពាក្យថា **ខេមរ** មកពី " ខិ +មៈ +រៈ "ប្រែថា "ក្សេមល្អ ការរក្សានូវប្រយោជន៍ដែលបានហើយ " ។

ដូច្នេះត្រង់ពាក្យថា ខ្មែរ ដែលសម្ដេចព្រះសង្ឃរាជព្រះអង្គទ្រង់យល់ថាទំនងជាមកពីមគធ ភាសាថា **ខេមរៈ** នោះ បើតាមការពិចារណារបស់ខ្ញុំ ខ្ញុំយល់ថាពិតជាមកពីពាក្យថា **ខេមរៈ** នោះមែន ពីព្រោះកាលខ្ញុំនៅវត្តពីក្មេងនោះខ្ញុំធ្លាប់បានមើលឃើញ នៅក្នុងសាស្ត្រាស្លឹករិត ដែលចាស់ពីបុរាណកាលបានចារសរសេរអក្សរតម្រួតគ្នារបៀបនេះច្រើនណាស់ "(គឺយកព្យញ្ជនៈដើមព្យាង្គទៅត្រួតលើព្យញ្ជនៈប្រកបដូចជាត្មា =តាម-ថ្ទៃទ្វាំ = ថែមទាំង ផ្ទើ = ផើម ។ ល ។)

ដោយអាស្រ័យហេតុដូចមានចង្អុលខាងលើនេះលោកពៅ ឈិនជឿថា **ខេមរ** ›**ខ្មេរ** ›**ខ្មែរ** (ស្រៈអែកើតមក ពីការនិយមរបស់ខ្មែរក្នុងការអានស្រៈ េ -បាលី-សំស្ក្រឹត) ។

ចំពោះពាក្យ **ខម** លោកពៅ ឈិនបានសរសេរថា "មួយទៀតពាក្យថា ខម នេះបើថាវាក្លាយមកពីពាក្យដើមថា "ខមៈ+អ " ដែលប្រែថា "អត់ អត់ធន គួរ " ឬថា " ផែនដី "នោះវិញក៏បានដែរ ដោយហេតុថា ខ្មែរយើងនេះជាអ្នកទទួលអរិយធម៌ព្រះពុទ្ធសាសនាដែលមានអវិហិង្សាធម៌ គឺត្រូវមានចិត្តគំនិតអត់ធន់ មិនបៀតបៀនមនុស្សសត្វទូទៅជាប្រធាន " ។

ចំពោះពាក្យ **កម្ពុជា** លោកពៅ ឈិន បានសរសេរថា "...ព្រះថោងនោះបានផ្លាស់នាមប្រទេសពី **នគរគោកធ្លក**នោះមកជា **ក្រុងកម្ពុជាធិបតី** ។ ថាបានជាអោយឈ្មោះថា **ក្រុងកម្ពុជាធិបតី** វិញនោះ ពីព្រោះចង់ប្រើជំនួសពាក្យថា **សុវណ្ណភូមិ** ប្រែថា "កន្លែងកើតមាស "ដោយហេតុពាក្យទាំងពីរនេះមានន័យថា "កន្លែងកើតមាស "ដូចគ្នា ។ ថាចុះហេតុអ្វីក៏ចាំយកពាក្យថា **កម្ពុជា** មកប្រើជំនួសពាក្យថា **សុវណ្ណភូមិ** បើពាក្យទាំងពីរនេះមានន័យដូចគ្នាទេ ? ត្រង់នេះថាវាមកពីពួកមន ដែលគេបាននៅតាមមាត់ទន្លេមេណាមរហូតទៅដល់ខាងត្បូងប្រទេសភូមាក្នុងជ្រោយសុវណ្ណភូមិ ជាមួយគ្នាដែរនោះ គេបានតាំងជារដ្ឋអំណាចមួយដែរ " ។

## ៥. ទស្សនៈរបស់លោក មាស ហាំ

លោក មាស ហាំមន្ត្រីចូលនិវត្តន៍ម្នាក់បានសរសេរក្នុងអត្ថបទ "ពង្សាវតារអក្សរខម "(វាយអង្គុលីលេខ) ថា : "នៅប្រទេសឥណ្ឌាមានរដ្ឋមួយហៅថា **ខមបុត្ត** ឬ **ខមពុជ**ឬ**កមបុត្ត** ឬ**កមពុជ** ។ ដូច្នេះយើងអាចនឹងយល់បានថា ដោយហេតុតែអ្នកស្រុករដ្ឋ **ខមពុជ** ឬ **កម្ពុជ** មកតាំងទីលំនៅ នៅប្រទេសគោកធ្លកច្រើន ហើយអ្នកទាំងនោះសុទ្ធសឹងតែអ្នកមានជំរេះវិជ្ជាឆើតឆាយជាជាងអ្នកស្រុកជាតិដើមនៃនគរគោកធ្លកក៏ប្រែឈ្មោះនគរគោកធ្លកអោយទៅជា **កម្ពុជា** តមក ។

ឯត្រង់ពាក្យហៅទៅពលរដ្ឋវិញ គេហៅ **កម** ទៅដូចជាពុំស្របតាមពាក្យសំដីខ្មែរ ។ ដូច្នេះ គេហៅថា ខមទៅវិញ ។

ដោយហេតុតែជាតិ ខម ស្និទ្ធស្នាលជាមួយអ្នកគោកធ្លកទើបគេហៅថា **ខេមមរះ** (ភ្លើម្រាក់) ដែលក្លាយទៅទៀតថា **ខេមរះ**តែដោយពាក្យនេះវែងពិបាកនិយាយ ទើបកែថា **ខមមែ** ដែលក្លាយទៅជា **ខ្មែរ** ។

## ៦. ទស្សនៈលោក ហ៊ឹម ខាន់

លោក ហ៊ឹម ខាន់ជានាយទាហានម្នាក់នៃកងទ័ពជាតិខ្មែរ ។ ក្នុងអត្ថបទវាយអង្គុលីលេខ "ខមធិប្បាយ) លោកបានពន្យល់ថា : "ពួក **នាគ** ដែលជាម្ចាស់ដើមនៃប្រទេសឥណ្ឌា ត្រូវខ្ចាត់ខ្ចាត់មកសុវណ្ណភូមិដោយច្បាំងចាញ់ពួក **គ្រុឌឈ្លានពាន** (**ពួកអារ្យ**) ។ មុននាគមកដល់ គេឃើញដែនដីសុវណ្ណភូមិមានម្ចាស់ដើមហើយគឺពួក**ខែ** និងពួក **មន** ក៏ប៉ុន្តែលោកអ្នកប្រាជ្ញភាគច្រើនបានអះអាងស្របគ្នាថា ទីស្ថាននេះត្រូវអ្នកបស្ចិមប្រទេសធ្វើឥណ្ឌូបនីយកម្ម ទាល់តែក្លាយទៅជាប្រទេសឥណ្ឌាទី ២ តាំងពីច្រើនរយឆ្នាំមុនសម័យពុទ្ធកាលម្ល៉េះ ។ ពួកមនរមញ្ញជាអ្នកគោរពព្រះអាទិត្យ រីឯពួកខែ (គឺខ្មែរយើងនេះ)ជាអ្នកគោរពព្រះចន្ទ ។ ចម្បាំងបានកើតឡើងរវាង ពួកនាគនិងពួកខែ -មន ហើយទោះបីជ័យជំនះបានទៅពួកនាគក៏ដោយ ក៏មួយភាគធំត្រូវក្លាយជាខែ ហើយមួយភាគទៀតក្លាយទៅជាមន ។ តាំងពីកាលនោះមកនាមនាគក៏កាន់តែបាត់ទៅៗ ។ គេពុំដឹងប្រាកដថា ជនជាតិខែរួមនិងមនហៅថា **ខម**ពីសម័យណាទេ ។ អ្នកខ្លះហៅខមទៅជា **ក្រម ត្លម យុមខាំ ចាម សៀម លខ ឈ្វេ** ក៏មាន ។ គេថា ខមនេះច្រើនមានពណ៌សម្បុរខ្មៅ ។ ក្នុងសៀវភៅចិន្តាមុនីចែងថា **ខម** ឬ ខ្មែរជាជាតិសាសន៍តែមួយ ។ **ខ្មែរ ខេមរ** និង **កម្ពុជា** មានន័យដូចគ្នា " ។

## ៧. ទស្សនៈលោក ឆត្រា ប្រេមឬឌី

លោកឆត្រា ប្រេមឬឌីជាអ្នកស្រាវជ្រាវខ្មែរម្នាក់នៅបរទេស ។ ក្នុងអត្ថបទមួយមានចំណងជើងថា "ខ្មែរមកពីណា ?"ផ្សាយតាមវិទ្យុជាតិ កាលពីខែ កុម្ភៈ ១៩៧៣ លោកបានបញ្ចេញយោបល់របស់លោកថា កាលពីសម័យបុរាណប្រទេសខ្មែរផ្នែកខាងលើហៅថា **ជាន់លើ** ឯផ្នែកខាងក្រោមហៅថា **ក្រោមពុជ** ។ ពាក្យនេះក្លាយមកទៀតទៅជា **ក្រមពុជ** រួច **កមពុជ** រួច **កម្ពុជា** ឬ **ខម** ។

## ៨. ទស្សនៈលោក កេង វ៉ាន់សាក់

ក្នុងសម័យប្រជុំពេញអង្គ នៃក្រុមប្រឹក្សារាជាណាចក្រ(ឥឡូវព្រឹទ្ធសភា) ស្ដីពីការបង្កើតវិទ្យាស្ថានខ្មែរ-មន កាលពីថ្ងៃ១៦ខែ កុម្ភៈ ឆ្នាំ១៩៧០ លោកកេងវ៉ាន់សាក់ បានថ្លែងបំភ្លឺអង្គប្រជុំចំពោះពាក្យ **ខ្មែរ**និង **កម្ពុជា** មានសេចក្ដីដូចតទៅ ៖

- ពាក្យ ខ្មែរ ក្លាយមកពីពាក្យ **ក + មេ** ។ ហេតុបានជាដូច្នោះ ព្រោះខ្មែរយើងជាអ្នកនិយមទុកស្រីជាធំក្នុងគ្រួសារនិងក្នុងសង្គម បានសេចក្ដីថា ខ្មែរយើងជាអ្នកមេនិយម(matriarcaliste ) ។ បុព្វបទ "ក "មាននាទីធ្វើន័យរបស់ពាក្យណាមួយមានលក្ខណៈកាន់តែខ្លាំងក្លាឡើង ដូច្នេះ **ក+មេ** មានន័យថា អ្នកគោរពមេខ្លាំងជាងអ្នកឯទៀតដែលគោរពល្មមៗ ឬគោរពឪពុកទៅវិញ ។

  **ក + មេ › កមេ › ក្មេ › ក្មេរ > ខ្មេរ › ខ្មែរ**

- ពាក្យ **កម្ពុជា** ក្លាយមកពី **ក +ពុជា** ។ ហេតុបានជាគេហៅខ្មែរយើងថា **ពុជា** ព្រោះយើងពុំដែលធ្វើខ្ញុំកញ្ជះអ្នកឯទៀតឡើយ ។ ហើយដើម្បីអោយឃើញន័យកាន់តែខ្លាំង គេដាក់បុព្វបទ "ក"ពីមុខមកទៅជា **ក +ពុជា** > **កពុជា** ដែលអ្នកបាលី-សំស្ក្រឹតនិយមសរសេរទៅជា **កម្ពុជា** ដូច្នេះទៅវិញ ។

សរុបសេចក្ដីមក យើងឃើញថាទស្សនៈចំពោះពាក្យថា **ខ្មែរ** -**ខម**- **កម្ពុជា**នេះមានច្រើនមែនតែមិនទាន់ចុះសំរុងគ្នានៅឡើយ ។ ភាគច្រើនបានខិតខំពន្យល់ពាក្យ ទាំងនេះដោយនិយមភ្ជាប់ទៅឫសគល់ឥណ្ឌា មានតែលោកកេង វ៉ាន់សាក់ម្នាក់ទេដែលបានយក ឫសគល់ **ខ្មែរ-មន** មកធ្វើជា មូលដ្ឋានក្នុងការពន្យល់នេះ ។ គួរកត់សំគាល់ថា ពាក្យខ្មែរនេះច្បាស់ជាបានក្លាយមកពីពាក្យ **ខ្មេរ**(សម័យអង្គរ) ដែលបានក្លាយមកពី "**ក្មេរ** "ទៀត(សម័យមុនអង្គរ) ។ គួរកត់សំគាល់ម្យ៉ាងទៀតថា ខ្មែរយើងនិយមហៅខ្លួនឯងថា **ខ្មែរ** ឯប្រទេសយើង យើងហៅថា **ស្រុកខ្មែរ** ។ ពាក្យថា**កម្ពុជា**បានក្លាយមកពីពាក្យ **កម្វុជា**ដែលមានប្រើក្នុងសិលាចារឹក(ព្រះគោល) ឬ **កម្វុជទេស**(បន្ទាយឆ្មារ) ។ សិលាចារឹកចាមក៏មាន

ប្រើពាក្យ **កម្វុជទេស**នេះសំរាប់សំគាល់ប្រទេសខ្មែរយើងដែរ ។ សិលាចារឹកបក្សីចាំក្រុង នៅស.វ.ទី ១០បានពន្យល់ថា ស្តេចកម្ពុជាមានដើមកំណើតមកពីឥសី **កម្ពុ**និងនាងអប្សរ **មេរា** ។ បើដូច្នេះឃើញថា ពាក្យ **កម្ពុជា** មានជាប់ទាក់ទងនឹងស្តេចឬរាជវង្សនេះច្រើន ។ តើពាក្យ **កម្ពុជា**នេះត្រូវគ្នានឹងពាក្យចិនថា **ចេនឡា** ឬទេ ? ព្រោះជនជាតិនេះច្រើនតែងហៅប្រទេសយើងថា **ចេនឡា** តាំងតែពីចេនឡាជារដ្ឋចំណុះរបស់ហ្វូណនរហូតដល់ពេលវាយ ហ្វូណន ពង្រីកអោយទៅជាចេនឡាធំ គឺនៅពេលដែលមានប្រើពាក្យ **កម្វុទេស** ក្នុងសិលាចារឹក ។ ឯជនជាតិយួនក៏បានប្រើពាក្យ **ចិនឡាប** (= **ចេនឡា**) តមកទៀត សំរាប់សំគាល់ប្រទេសខ្មែរ នៅសម័យក្រោយអង្គរ គឺក្នុងសម័យដែលស្តេចខ្មែរមានឋានន្តរនាម ថា **ក្រុង កម្ពុជាធិបតី** ។

គួរកត់សំគាល់ជាបន្ថែមទៀតថា ពាក្យខ្មែរនេះត្រូវបានជនជាតិបរទេស ស្គាល់យូរណាស់មកហើយ ។ ចិនហៅយើងថា **គីម៉ាច** អារ៉ាប់ហៅថា **គោម៉ារ** (Qomar) ចាមហៅ ក្វិរ-ក្មិរ យួនហៅ **កាវមេន** ឬ **កាវមៀន** សៀម-លាវហៅ **ខម** ។ ចំពោះពាក្យ **ខម**នេះ លោកពញា អនុមាន **រាជធន** អ្នកប្រាជ្ញថៃខាងអក្សរសាស្ត្របានសរសេរក្នុងសៀវភៅ "Thai literature in relation to the diffusion of her cultures "ថា Who were tho Khoms ? They were probably a race of people akin to the Mons and the Khmers or Cabbodians of the presentday .The old-mon alphabet and also the old Khmer alphabet were called khom by the Thai " ។ បើតាម ន័យខាងលើពាក្យ **ខម**ទំនងជាកើតមកពី **ខ(ខ្មែរ)+ម(មន)** ទេដឹង ? ព្រោះខ្មែរយើងមិននិយមហៅខ្លួនឯងថា **ខម**ទេ មានតែសៀម លាវ ហើយពួកនេះមានការកោតស្ញប់ស្ញែងចំពោះពួក**ខម**នេះណាស់ ព្រោះ**ខម**(ខ្មែរ +មន?)ជាអ្នកមានអរិយធម៌ខ្ពង់ខ្ពស់ដែលបានជះឥទ្ធិពលទៅលើពួកសៀម លាវ យ៉ាងសម្បើម ។

## ខ. មន

ក្នុងអំបូរខ្មែរ-មន **មន**ជាធាតុមួយសំខាន់បន្ទាប់ពីខ្មែរមក ។ យ៉ាងណាមិញ ក្នុងអតីតកាលមនជាជាតិមួយធ្លាប់ថ្កុំថ្កើងរុងរឿង មានទឹកដីធំទូលាយមានប្រវត្តិសាស្ត្រយូរអង្វែងមកហើយ ។ ដូនតាខ្មែរបុរាណស្គាល់ជាតិមននេះច្បាស់ណាស់ បានជាលោកចងក្រងទំនុកច្រៀងនិងបទភ្លេងជាច្រើនដែលមានទាក់ទងនិងជនជាតិនេះដូចជាបទ "មនមុជទឹក "បទ "សំណាមន " ។ល ។

ជនជាតិមនហៅខ្លួនឯងថា **មន** ប៉ុន្តែជនជាតិភូមាបែរជាហៅជាតិនេះថា **តះឡាញ់** ( Talaing) វិញ ។ តើពាក្យថា**មន**នេះមានន័យសេចក្តីដូចម្តេច? ហើយពាក្យថា **តះឡាញ់**នោះមានន័យសេចក្តីដូចម្តេចទៀតដែរ?

ជនជាតិមនបានបញ្ជាក់ថាគេពុំដែលប្រើពាក្យអ្វីដទៃក្រៅពីពាក្យ **មន** សំរាប់សំគាល់ខ្លួនគេទេ ហើយគេបានបញ្ជាក់ទៀតថាតាមទស្សនៈរបស់អ្នកប្រាជ្ញខ្លះពាក្យ**មន**នេះទំនងជាក្លាយមកពីពាក្យបាលី **មនុ** ហើយមានន័យថាប្រជាជាតិដែលមានមហិទ្ធិរិទ្ធិខ្លាំងពូកែ ។

នៅក្នុងសិលាចារឹកបុរាណគេឃើញមានប្រើពាក្យថា **មេិញ** ដែលអ្នកសិក្សាស្រាវជ្រាវសន្មតថាបានវិវត្តបន្តិចៗ ដូចខាងក្រោមនេះ

**មេិញ** › **រមេញ** › **រមញ** › **មញ** › **មន៍**

សព្វថ្ងៃនេះ ជនជាតិមនជួនកាលសរសេរថា **មញ** ជួនកាលសរសេរថា **មន៍** ។

ចំពោះ ថា **តះឡាញ** វិញ មានទស្សនៈច្រើនបែបយ៉ាងដែលខិតខំពន្យល់ ។ នៅទីនេះយើងសូមលើកយកតែបីមកជំរាបដូចតទៅនេះ ៖

១. ទស្សនៈដែលយល់ថា **តះឡាញ** ក្លាយមកពី តយឡួយ (Toi-loin) ។ **តយ** មានន័យថា " មិច្ឆាទិដ្ឋិជន "ឯ **ឡញ** មានន័យថា "ត្រូវវិនាសអន្តរាយ " ។ **តយឡួយ** មានន័យថា "ពួកមិច្ឆាទិដ្ឋិជនទាំងឡាយត្រូវវិនាសអន្តរាយ " ។

ទស្សនៈបែបនេះមានសំអាងលើរឿងព្រេង ដែលនិទានថា ក្នុងអតីតកាលមានព្រះមហាក្សត្រមួយអង្គមាននាមថា **តិសះ** សោយរាជ្យនៅនគរថាទង ។ កាលណោះមានពួកមិច្ឆាទិដ្ឋិជន វាមកញុះញង់ស្តេចអង្គនេះអោយយល់ខុសជាត្រូវ ដោយបោះបង់ចោលនូវជំនឿលើព្រះពុទ្ធសាសនា ព្រះពុទ្ធរូបទាំងឡាយ ត្រូវបញ្ជាអោយយកទៅបោះចោលក្នុងទឹកទន្លេ ។ គ្រានោះ មានកូនស្រីសេដ្ឋីម្នាក់មានឈ្មោះហៅថា **មិត្តឆ្វ**នាងនោះជាពុទ្ធសាសនិកយកចិត្តទុកដាក់គោរពបូជាព្រះពុទ្ធខ្លាំងណាស់ ហើយដោយមិនបានដឹងពីបញ្ជារបស់ស្តេចទមិឡឈ្មោះ **តិសះ** ក៏បានស្រង់យកព្រះពុទ្ធបដិមាករខ្លះដែលគេទំលាក់ក្នុងទឹកទន្លេ យកទៅតំកល់ទុកក្នុងផ្ទះនាង ។ អាស្រ័យដោយហេតុនោះ នាងក៏ត្រូវកាត់ទោសប្រហារជីវិតដោយដុតនឹងភ្លើង និងដោយអោយដំរីជាន់ ក៏ប៉ុន្តែទោះបីពួកពេជ្ឈឃាតខិតខំប្រើគ្រប់មធ្យោបាយយ៉ាងណាក៏ដោយ ក៏ពុំអាចសំលាប់នាងបាន ។ ដោយងឿងឆ្ងល់ខ្លាំង ស្តេចក៏សួរទៅនាងថា តើនាងមានចេះមុនវិជ្ជាគាថាអ្វីទេ? នាងឆ្លើយថា នាងពុំមានសិល្បសាស្ត្រអ្វីក្រៅពីជំនឿដ៏មុតមាំលើព្រះពុទ្ធឡើយ ។ ស្តេច **តិសះ** យល់កំហុសរបស់ខ្លួន ក៏វិលទៅរកព្រះពុទ្ធសាសនាជាថ្មីឡើងវិញ ។ បន្ទាប់មកក៏បញ្ជាអោយចាប់ពួក មិច្ឆាទិដ្ឋិជនទាំងឡាយ ព្រមជាមួយនឹងញាតិសន្តានទាំងអស់យកទៅកប់ត្រឹមក សម្លាប់ដោយភ្ជួរពីលើ ។ ខ្លះទៀតដែលមិនចង់ស្លាប់ដោយវិធីនោះ ក៏រត់ទៅលោតទឹកធ្វើ អត្តឃាតទៅ ។ ដូច្នេះពួកមិច្ឆាទិដ្ឋិជនទាំងឡាយត្រូវស្លាប់វិនាសអស់រលីងពីនគរ ។

ក្នុងភាសាមន "ពួកមច្ឆាទិដ្ឋិជនទាំងឡាយត្រូវវិនាសអន្តរាយ" គេនិយាយថា **តយឡុយ** ទើបមានជនខ្លះយល់ស្មានថា យូរៗទៅពាក្យនេះក៏ប្រែក្លាយទៅជា **តះឡាញ់** ដែលជនជាតិភូមាប្រើសំគាល់ជាតិមននេះឯង ។

២. ទស្សនៈដែលយល់ថា **តះឡាញ់** ក្លាយមកពីពាក្យភូមាពីរម៉ាត់គឺ **តាន** និង **ឡាញ** (Tan lgaing) ។ នេះគឺជាទស្សនៈរបស់អ្នកប្រាជ្ញភូមាម្នាក់ឈ្មោះ **អ៊ូឆាន់ម្យ៉ះ** ( U Chan Mya) សាស្ត្រាចារ្យអក្សរសាស្ត្រនៅសកលវិទ្យាល័យម៉ាន់ **តះឡេ** (Mandalay) ។ លោកនេះយល់ថា **តាន** មានន័យថា **ទឹក** ឯ **ឡាញ** មានន័យថា **ចំរើនលូតលាស់ខ្លាំង ឬ កន្លែងដែលមានទឹកជោរជន់** ។ ចំណេរតមកពាក្យ **តាន** ក្លាយជាពាក្យ **តះ** ហើយ **ឡាញ**ក្លាយជា **ឡ្លាញ** (hliang) ។ នៅទីនេះពាក្យ **តះ**គ្មានន័យសេចក្តីអ្វីអោយពិតប្រាកដទេ ។ **ឡ្លាញ**វិញមានន័យថា **រលក ឬ រលកធំៗ** ។ ចំពោះអ្នកប្រាជ្ញរូបនេះ ប្រទេសមនដែលស្ថិតនៅក្នុងប្រទេសភូមា ខាងត្បូងសព្វថ្ងៃ ជាតំបន់ស្ថិតនៅតាមឆ្នេរសមុទ្រហើយដែលតែងតែមានភ្លៀងធ្លាក់ជោកជាំផងនោះសមជាមាន ឈ្មោះហៅថា **តានឡាញ** ណាស់ ហើយយូរៗទៅក៏គេប្រើពាក្យនេះសំរាប់សំគាល់ជនជាតិដែលរស់នៅទីនោះតែម្តង គឺជនជាតិមនហ្នឹងឯង ។ទស្សនៈបែបនេះឃើញថាមានលក្ខណៈសមហេតុសមផលច្រើន គួរយកទៅពិចារណា ក៏ប៉ុន្តែគេពុំឃើញប្រើពាក្យនោះក្នុងសិលាចារឹកសំរាប់សំគាល់ជនជាតិមនសោះឡើយ ។

៣. ទស្សនៈទី ៣ ដែលចាត់ទុកថា **តះឡាញ់** ក្លាយមកពីពាក្យ**តេលិង្គណ**ដែលជាតំបន់មួយស្ថិតនៅលើឆ្នេរសមុទ្រខាងកើតនៃប្រទេសឥណ្ឌា ។ តាមទស្សនៈនេះគេយល់ថាជនជាតិឥណ្ឌាកាលពី ដើមបានមកធ្វើជំនួញនៅប្រទេសមន ហើយបានរៀបការជាមួយនិងស្រីមន តែលុះដល់ត្រឡប់ទៅស្រុកកំណើតវិញពុំបាននាំប្រពន្ធកូនទៅជាមួយផងទេ ។ ចំពោះពួកមនជាកូនទាំងនោះ ហើយដែលគេអោយឈ្មោះហៅថា **តះឡាញ់** គឺមានន័យថា **គ្មានបា ឬ កូនឥតបា** ក៏ប៉ុន្តែ ចំណេរតមកពាក្យ **តះឡាញ់** នេះក៏បានប្រើជាទូទៅសំរាប់ជនជាតិមនទាំងមូល ។ ជាការពិតណាស់ថាក្នុងបុរាណកាលជនជាតិឥណ្ឌា និងមនមានការប្រាស្រ័យទាក់ទងនឹងគ្នាជាច្រើន ។ ជាភស្តុតាងគឺជនជាតិមនបានទទួលឥទ្ធិពលវប្បធម៌ពីជនជាតិឥណ្ឌាជាច្រើន មានតួអក្សរនិងព្រះពុទ្ធសាសនាថេរវាទជាដើម ។ ក្នុងទំនាក់ទំនងរវាងជនជាតិទាំងពីរនេះទំនងជាមានពួកឥណ្ឌាមកពីតំបន់តេលិង្គណមែនហើយ ។ លោកសឺដែស (Coedès) ក៏មានយោបល់ដូចនេះដែរ : "L'appellation de Talaing, appliquée aux Môns par les Birmans, semblc indiquer qu'à une certaine époque le Telingana ou région de Madras fut enrelations particulièrement actives avec le pays môn" តែការដែលយកពាក្យថា **តះឡាញ់** ប្រើសំរាប់សំគាល់ជនជាតិមនទាំងអស់ហាក់ដូចជាពុំសមរម្យ ។ តាមយោបល់របស់ជនជាតិមនផ្ទាល់ថាពាក្យ **តះឡាញ់** ដែលមានន័យថា **កូនឥតបា** ជារឿងប្រឌិតឡើងដើម្បីបង្ខូចកេរ្តិ៍ឈ្មោះ

របស់ជាតិគេតែប៉ុណ្ណោះ ។ តាមការពិត ពាក្យ តះឡាញ់ នេះមានន័យថា **បាត់បង់ឪពុក** ឬ **ឪពុកត្រូវបាត់បង់** ហើយបានក្លាយមកពីពាក្យ **ឥត ឡញរះ**(l'ta loin ra) ។ ពាក្យថា**ឥតះ** ឬ **តះ** នេះមានន័យថា ឪពុក ឯពាក្យថា **ឡញរះ** មានន័យថា **បាត់បង់** ឬ **វិនាស** តែនៅទីនេះពាក្យថា **ឥតះ** ពុំមែនសំគាល់ត្រឹមតែឪពុកជាមនុស្សម្នាក់ឬច្រើននាក់ប៉ុណ្ណោះទេ តែសំគាល់នូវទឹកដីទាំងមូលជាកេរដំណែលពីដូនតារបស់ជនជាតិមនតែម្តង ។ សូមជ្រាបថា ក្នុងគ្រាដែលជនជាតិភូមាវាយលុកចូលក្នុងរដ្ឋមន ជនជាតិនេះរត់គេចពីភូមិស្រុកបណ្តើរស្រែកបណ្តើរថា **ឥតះ ឡញរះ**!បានសេចក្តីថា **ទឹកដីឪពុកយើងត្រូវវិនាសអន្តរាយអស់ហើយ**តែពាក្យខាងដើមគឺ **ឥ** និង ពាក្យខាងចុង : លឺមិនសូវច្បាស់ នៅសល់តែពាក្យ **តះឡញ**ដែលក្លាយទៅជា **តះឡាញ់**តាមសំដីរបស់ជនជាតិភូមាតែម្តងទៅ ។ តើជនជាតិដែលមានឈ្មោះថាមននេះ មានគ្នាប៉ុន្មាននាក់ ហើយរស់នៅទីណាខ្លះ ? និងជាពិសេសតើជនជាតិនេះមានប្រវត្តិពីខាងដើមរៀងដូចម្តេចខ្លះដែរ ?

បើតាមពត៌មានដែលយើងបានទទួល ឃើញថាមនមានចំនួនសរុបប្រហែល ៧លាននាក់ ។ ក្នុងប្រទេសភូមា ទីកន្លែងដែលជនជាតិនេះរស់នៅច្រើនកុះករបំផុត គឺតំបន់ឆ្នេរសមុទ្រតេណាស្សេរីម (Tenasserim)និងបេគូ (Pegu) ។ ប៉ុន្តែនៅរដ្ឋធានីយ៉ាងកូង (Rangoon) និងក្នុងភូមិឆ្ងាយដាច់ស្រយាលស្ថិតនៅខាងលិច ក៏មានជនជាតិមនរស់នៅខ្លះដែរ ។ ជនជាតិមនក្នុងប្រទេសថៃមានចំនួនតិចជាងប្រទេសភូមា ហើយច្រើននៅជិតៗក្រុង បឹងកក់ នៅជុំវិញកាន់បុរី (ពួកនេះជាកូនចៅរបស់ជនភៀសខ្លួន នៅស.វ.ទី១៨-១៩)នៅលព្វបុរី នៅឧថៃថានី និងនៅជិតនគររាជ ។

ប្រពៃណីប្រវត្តិសាស្ត្រមនបានដំណាលថា ជនជាតិមនមានកំណើតនៅត្រង់ថាទង (សុធម្មវតី) នៅប្រមាណ ៦០០ឆ្នាំមុន គ.ស.ម្ល៉េះ ។ តែចម្លែកត្រង់សព្វថ្ងៃហាក់ដូចជាគ្មានសល់អ្វីជាដុំកំភួន ល្មមអោយចាត់ទុកទីនោះ ថាជារាជធានីចាស់ ឬមួយបុរាណវត្ថុដែលនៅសល់ត្រូវកប់បាត់ទៅក្នុងដីអស់ទៅហើយ ? បើយើងពឹងផ្អែកទៅលើឯកសារចិន ឃើញថាជនជាតិមនបានបង្កើត រដ្ឋទ្វារវតីនៅស.វ.ទី៧ ដែលមានទីតាំងនៅត្រង់វាលទំនាបខាងក្រោមនៃទន្លេមេណាមក្នុងប្រទេសថៃសព្វថ្ងៃ ។ ប៉ុន្តែបើតាមប៉ានស្មានមើលទៅរដ្ឋនេះប្រហែលកកើតឡើងនូវមុន ស.វ.ទី៧ ព្រោះនៅត្រង់ព្រះបឋមពងទឹក ដែលស្ថិតនៅក្នុងរដ្ឋទ្វារវតីគេបានរកឃើញ វត្ថុជាច្រើនដែលមានកាលកំណត់ មុនពាក់កណ្តាលស.វ.ទី៦ ។ ចិនប្រហែលមិនបានស្គាល់រដ្ឋនេះមុនស.វ.ទី ៧ ព្រោះវានៅមិនចំផ្លូវជំនួញ ។ នៅក្រោយកាលកំណត់នេះបន្តិច ក្រោមកិច្ចដឹកនាំរបស់ព្រះនាងឆាម្មទេវីជនជាតិមនបានកសាងរដ្ឋមួយទៀតគឺរដ្ឋហរិបុញ្ជ័យនៅត្រង់វាលទំនាបខាងលើនៃទន្លេមេណាម ។ ប្រភពចិនបានអោយដឹងថែមទៀតថា រដ្ឋថ្មីមួយត្រូវបានស្ថាបនាឡើងមួយទៀត គឺរាជាណាចក្រហង្សវតីនៅឆ្នាំ៨២៥ដោយបងប្អូនភ្លោះពីរនាក់ ឈ្មោះ សមល និង វិមល ហើយរដ្ឋនេះស្ថិតនៅខាងត្បូងប្រទេសភូមានៅចន្លោះទន្លេ ឥរវតី និងសាល់វិន ។

គេបានដឹងថា នៅឆ្នាំ១០៥៧ ស្តេចអនោរថដែលបានបង្កើតរដ្ឋភូមាដំបូងគឺរដ្ឋបូកានបានលើកទ័ពទៅវាយមននៅថាទងហើយថែមទាំងបានចាប់យកជាឈ្លើយអស់ជាច្រើនទៅជាមួយផង ។ គួរកត់សំគាល់ថាក្នុងចំណោមឈ្លើយទាំងនោះ មានអ្នកប្រាជ្ញបណ្ឌិតកវីជាច្រើនដែលបានផ្សាយអរិយធម៌របស់ខ្លួនដល់ពួកអ្នកឈ្នះ មានតួអក្សរនិងលទ្ធិពុទ្ធសាសនាថេរវាទជាដើម ។ មកដល់ស.វ.ទី១៦គឺក្នុងឆ្នាំ ១៥៤០មេទ័ពភូមាម្នាក់មកពីតងអ៊ូ (Taungo) បានបង្កើតរាជវង្សថ្មីមួយទៀត ហើយលើកទ័ពទៅវាយក្រុងបេគូយកធ្វើរាជធានីរបស់ខ្លួនរហូតតទៅ ដែលជាហេតុបណ្តាលអោយជនជាតិមនបាត់បង់ឯករាជ្យ អធិបតេយ្យរបស់ខ្លួន ហើយចាប់ពីពេលនោះមកក៏អស់មានឋានៈជារដ្ឋរស់នៅបែកខ្ញែកគ្នា ហើយចំនួនប្រជារាស្ត្រក៏កាន់តែរលោះទៅៗ រហូតដល់សព្វថ្ងៃ ដោយហេតុតែមានការបង្ក្រាបដោយសម្លាប់រង្គាលបន្ទាប់ពីមានការបះបោរទាមទារសេរីភាពពីរលើកគឺក្នុងរជ្ជកាលស្តេចបាយិណោងម្តង (១៥៥១-១៥៨១) និងដោយមេទ័ពអាឡោងផាយ៉ាម្តងក្នុងឆ្នាំ១៧៥៧ ហើយប្រហែលជាដោយហេតុនេះហើយ បានជាជនជាតិភូមានិយមហៅមនថា **តះឡាញ់** (មនថា តះឡើង-ខ្មែរថា ថ្លើង ក្នុងពាក្យថ្លើងបះ គឺអ្នកចូលចិត្តបះបោរ) ។

# បញ្ជីឯកសារពិគ្រោះ

1 - Adhémard Leclére, l'Histoire du Cambodge, Geuthner, Paris 1914.

2 - Pierre Gourou, l'Asie, Paris, 1971.

3 - G . Olivier. les populations du Cambodge. Paris1956.

4 - B.P. Groslier Indochine, carrefour des arts, éditions Albin Michel, Paris,1961.

5 - Henri V. Valloi , les races humaines, PUF, Que Sais-je ? Paris1967.

6 - Maurice Glaize les monuments du groupe d'Angkor, Paris 1963.

7 - Revue France- Asie, n• spécial pour la civilisation khmère, 1954

8 - អំបូរខ្មែរ និងអាស៊ីអគ្នេយ៍-អត្ថបទចុះក្នុងសារពត៌មានប្រយោជន៍ខ្មែរពីលេខ១៤៧ថ្ងៃទី២៨ កញ្ញា១៩៧០ដល់លេខ១៥២ថ្ងៃ ៦តុលា ១៩៧០ ។

9 - J . Deniker . les races et les peuples de la terre , Paris , 1926.

10 - B.P . Groslier, Découvertes archéologiques récentes au Cambodge, dans kambuja n°16, juillet 1966.

11 - Monuments historiques et sites, dans Final Report Volume ll of Preparatory Conference on the restoration and animation of historical sites for the Purpose of establishing the ARCAFA Phnompenh,1973.

12- B.P. Groslier, Angkor, hommes et pierres, Arthaud, 1956.

13 - G . Coedès, les Etats hindouisés d'indochine et d'Inedonésie, Paris 1964

14 - មុខងារស្ត្រីនៅសម័យអង្គរ ដោយនិសិត្សមួយក្រុមនៃវិញ្ញាបនប័ត្រ ឧត្តមសិក្សាផ្នែកវប្បធម៌ -អរិយធម៌ខ្មែរ-ភ្នំពេញ-១៩៧៣ ។

15- A . Bonifacio, Histoire classes terminales, Paris, 1966

16- Médecin- Colonel Lieurade, Généralités, sur les populations montagnard es du Sud indochinois, Bulletin de la Sociétè des Etudes indochinoises, Tome xxvi, 1951.

17- G. Coedès les peuples de la Péninsule indochinoise, Dunod , Paris ,1962

18- B.P. GRoslier, Indochine, éditions Nagel, Genève, 1966

19 - Henri Marchal, Angkor, Paris, 1955

20 - លោក ដួង សារិន - ប្រវត្តិសាស្ត្រកម្ពុជា - មហាវិទ្យាល័យអក្សរសាស្ត្រនិងមនុស្សសាស្ត្រ ភ្នំពេញ គ.ស. ១៩៦២-១៩៦៣ ។

21 - P. Fabricius, Prolégoménès à l'histoire du Cambodge, dans France - Asie, novembre - décembre 1960.